

PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554

- Life Insurance ធានារ៉ាប់រងជីវិត
- Car Insurance ធានារ៉ាប់រងរថយន្ត
- Refinance Your Debts រៀបចំសងប្រាក់ជំពាក់ឡើងវិញ
- Investments វិនិយោគទុន
- Office or Home Appointment. ជួបនៅការិយាល័យយើង ឬនៅផ្ទះលោកអ្នកក៏បាន

We also provide translation and interpretation services.
យើងផ្តល់ការបកប្រែភាសា តាមក្រដាស ឬផ្ទាល់មាត់

E-mail: 8665823172@primerica.gosolo.com

Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034



# ខ្មែរប៉ុស្តិ៍
# The Khmer Post



ហាងមាសរស្មី
SUNSHINE JEWELRY INC



- Fine Jewelry
- Certified Diamonds & Custom Design

មានលក់គ្រឿង អលង្កា យ៉ាងប្រណិតបំផុត ចេញសញ្ញាបត្រលើពេជ្រអាច ផ្លាក់ ឬ ថ្លៃ មាស ប្រាក់ ពេជ្រ ជូនបានតាមបំណង ។

យើងមានបទពិសោធន៍ ១៥ឆ្នាំ ហើយមានកេរ្តិ៍ឈ្មោះល្អក្នុងការបំរើសេវាអលង្ការនេះ

702 Washington Avenue Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com



CAMBODIAN-AMERICAN BIWEEKL NEWSPAPER

VOLUME 02 ISSUE 28 January 09th 2009 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM


## អ្នកប្រជាធិបតេយ្យត្រៀមបង្កើតគណបក្សតែមួយ

ដោយ: ស៊ឹម សុភាឫទ្ធិ



លោក កឹម សុខា និង អ្នកស្រី មូ សុខហួរ ធ្វើសន្និសីទកាសែត

•••បន្ទាប់ពីទទួលបរាជ័យការបោះឆ្នោតជ្រើសរើស

(តទៅទំព័រទី១៣)

## បណ្ឌិតអក្សរសាស្ត្រខ្មែរបានលាចាកលោកហើយ

ដោយ : ពិន សំខុន



•••លោកបណ្ឌិត កេង វ៉ាន់សាក់ ជាសាស្ត្រាចារ្យអក្សរសាស្ត្រដ៏ល្បីល្បាញ

(តទៅទំព័រទី១១)

## ថ្ងៃទី២០ មករា ជាថ្ងៃប្រវត្តិសាស្ត្រនៃអាមេរិកាំង

•••លោកបារ៉ាក់ អូបាម៉ា នឹងប្រែក្លាយពីប្រធានាធិបតីជាប់ឆ្នោតទៅជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ហើយថ្ងៃនោះប្រវត្តិសាស្ត្រប្រជាជាតិនឹងសរសេរពីប្រធានាធិតីសម្បុរស្បែកខ្មៅដំបូងបង្អស់របស់ពលរដ្ឋអាមេរិកកាំង បន្ទាប់ពីការតស៊ូទាមទារសិទ្ធយ៉ាងស្វិតស្វាញអស់ជាងមួយសតវត្សរ៍រួចមក។

សូមលោកអ្នករក្សាទំព័រក្នុងរបស់ខ្មែរប៉ុស្តិ៍ដែលមានរូបពណ៌របស់ប្រធានាធិបតីទាំង៤៤ របស់ពលរដ្ឋអាមេរិកាំង ទុកជាអនុស្សាវរីយ៍ ។

(តទៅទំព័រទី១២)





Mobile-net
We connect you to the world!
Since 1995



7.5¢
កម្ពុជា

ចុះឈ្មោះថ្ងៃនេះ នឹងទទួលបាន 133 នាទី សំរាប់ទូរស័ព្ទទៅកម្ពុជា ដោយឥតយកកំរៃ !

1.9¢ ថៃឡង់
5.5¢ លាវ

សេវាទូរស័ព្ទអន្តរជាតិ ដ៏ប្រសើរបំផុត

កក្តាក់ងារធ្វើការ

គ្មានកាលកំណត់
គ្មានយកកំរៃលើការភ្ជាប់ប្រព័ន្ធ
គ្មានយកកំរៃលើការថែទាំ
គ្មានតម្លៃប្រែប្រួល

my011.com
1(800) 818-9000


## ជំនួយសប្បុរសពីខ្មែរនៅសហរដ្ឋអាមេរិកដល់និស្សិតខ្មែរ



ដោយ " ខ្មែរប៉ុស្តិ៍ "

•••និស្សិតខ្មែរចំនួន១២៥នាក់ បានទទួលអាហារូបករណ៍សម្រាប់ឧត្តមសិក្សាឆ្នាំ២០០៨-២០០៩ ពី "មូលនិធិខ្មែរសម្រាប់ការសិក្សា" ដែលមានទីស្នាក់ការនៅវើស៊ីនញ៉ា នៃសហរដ្ឋអាមេរិក។ ពិធីផ្តល់អាហារូបករណ៍ដែលធ្វើឡើងនៅវិជ្ជាស្ថានបច្ចេកវិទ្យាកម្ពុជា កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨ គឺចែកជូនដល់និស្សិតសាកលវិទ្យាល័យចំនួន៩ រួមមាន : សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

វិជ្ជាស្ថានបច្ចេកវិទ្យាកម្ពុជា

សាកលវិទ្យាល័យបញ្ញាសាស្ត្រ

សាកលវិទ្យាល័យមេគង្គ អឺរ៉ុប និងសាកលវិទ្យាល័យបៀលប្រាយ

ពាក្យសុំអាហារូបករណ៍ប្រមាណ៣០០ បានត្រូវចំរាញ់ពីសិស្ស និងនិស្សិតពីទីក្រុង និងបណ្តាខេត្តនានា ក្រោមមូលដ្ឋានជាគ្រឹះ គឺផ្តល់លទ្ធិភាពសិក្សាស្មើភាពគ្នា។ លោកវេជ្ជបណ្ឌិត ខ្ចៅ សំរ៉ង ប្រធានមូលនិធិ បាននិយាយថា "ការចែកអាហារូបករណ៍នេះ គឺឈរទៅលើគោលការណ៍ ១- ភាពជាអ្នកប្រាថ្នាអត្ថប្រយោជន៍, ២- ភាពជាអ្នកដឹកនាំ និងចរិយាសម្បត្តិ "។

( តទៅទំព័រទី១៥ )

## ក្លឹបព័ត៌មាន

•••ដូចសន្យា "ខ្មែរប៉ុស្តិ៍ " ឆ្នេរខាងកើត បានអញ្ជើញជាលើកទី១ ដល់សាធារណជនមានអ្នកជំនាញ អ្នកធ្វើការ អ្នកគ្មានការងារធ្វើ មេផ្ទះ និស្សិត ...។ល។ មកចូលរួមពិសារភោជនាហារថ្ងៃត្រង់នៅភោជនីយដ្ឋាន " គោលដិន ប៉ាលាស" ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨ ។

ភ្ញៀវប្រមាណ៤០នាក់ បានចូលរួមដើម្បី ១- ជាការប្រាស្រ័យទាក់ទងលើកតម្កើងការរំលែកព័តិមានទៅវិញទៅមក, ២- លើកតម្កើងពាណិជ្ជកម្ម អាជីវកម្មក្នុងសហគមន៍, ៣- ពង្រឹងនិងគាំទ្រយុវវ័យ និងគ្រួសារ, ៤- បង្កើនថាមពលនៃសហគមន៍ ដោយផ្តល់នូវវេទិកា "ខ្មែរប៉ុស្តិ៍ " ជូនឱ្យប្រើ, ៥- ពង្រឹងទំនាក់ទំនងសហគមន៍ខ្មែរទៅសហគមន៍ផ្សេងៗទៀត ។

កម្មវិធីនេះ នឹងរៀបចំជូន១ខែម្តងដែល

(តទៅទំព័រទី១៦ )

# កូនខ្មែរពីរនាក់ត្រូវឃាតករបាញ់សម្លាប់ និង1700នាក់ត្រូវបញ្ជូនទៅកម្ពុជា

**ឡុងប៊ិច : ស្រីនាថ**



សង្សារមួយគូនេះ ត្រូវបានគេបាញ់សម្លាប់នៅថ្ងៃបុណ្យចូលឆ្នាំសកល ដោយបន្សល់ទុកនូវកូនតូចអាយុ 5 ឆ្នាំ (រូបថតក្រុមគ្រួសារសព)

កូនខ្មែរពីរនាក់ជា សង្សារនឹងគ្នា ត្រូវបាន ឃាតករមិនស្គាល់មុខ បាញ់សម្លាប់នៅនឹងកន្លែង ចតឡាន នៅមិនឆ្ងាយពីផ្ទះរបស់ខ្លួន កាលពីរំលង អធ្រាត្រ ចូលឆ្នាំថ្មីសកល ថ្ងៃទី1 ខែមករា ឆ្នាំ2009 នៅ ម្តុំ 1800 Block ផ្លូវ Gardenia Ave ក្បែរ តំបន់ Signal Hill ។

ជនរងគ្រោះដែលត្រូវឃាតករសម្លាប់ ឈ្មោះ វ៉ាន់ណាលី ទឹម អាយុ ២៤ឆ្នាំ ជាស្ត្រីសង្សា របស់ជនរងគ្រោះដែលស្លាប់ជាមួយគ្នានោះ ដែរ ឈ្មោះ សារិទ្ធ ឯម អាយុ២៥ឆ្នាំ ដោយបន្សល់ទុក នូវកូនប្រុសម្នាក់ឈ្មោះ អាដាម អាយុ 5 ឆ្នាំ ។

គ្មានពួកឃាតករណាម្នាក់ចេញមុខមកទទួល សារភាពនូវទោសកំហុសឧក្រិដ្ឋនោះ នៅឡើយ ទេមកដល់ពេលនេះ ។

ពួកមន្ត្រីប៉ូលិសនិយាយថា ក្រុមការងាររបស់ ខ្លួនកំពុងស្រាវជ្រាវនៅឧក្រិដ្ឋកម្មនោះហើយ ដោយការស៊ើបអង្កេត និងរុករកចាប់ខ្លួនឃាតករ មកកាត់ទោសតាមផ្លូវច្បាប់ ។ ក្រុមការងារស៊ើប អង្កេតរបស់ប៉ូលិសក៏ដូច FBI និយាយថា ពួកគេ ទទួលបាននូវព័ត៌មានពាន់ព័ន្ធជាបណ្តើរៗហើយ ប៉ុន្តែពួកគេច្រានចោល មិនអធិប្បាយឱ្យខ្មែរប៉ុស្តិ៍ ដឹងថា ករណីឃាតកម្មទៅលើគូសង្សារពីរនាក់ នោះថា បណ្តាលមកពីគំនុំបុគ្គល ឬករណីប្លន់ ឬ ឃាតកម្មសម្លាប់ដើម្បីអ្វីនោះទេ ?

សារិទ្ធ ឯម ធ្លាប់ធ្វើជាកងទ័ពអាមេរិកក្នុង រយៈពេល 3ឆ្នាំ បានទៅកាន់បេសកម្មធ្វើសង្គ្រាម នៅឯប្រទេសអ៊ីរ៉ាក់ និងអាហ្គានីស្ថាន ដើម្បីបុព្វ-ហេតុជាតិអាមេរិកផងដែរ ។

សហគមន៍ឡុងប៊ិច គឺជាមូលដ្ឋានប្រមូល ផ្តុំដែលមានខ្មែររស់នៅធំជាងគេបំផុតក្នុងសហ -រដ្ឋអាមេរិក ដែលជាតំបន់ជួបនូវព្រឹត្តិការណ៍ ឧក្រិដ្ឋកម្មផ្សេងៗ ការជួញដូរគ្រឿងញៀន បងធំ បងតូចបង្កើតក្រុមបក្សពួក បង្កបាញ់បោះសម្លាប់ គ្នាគ្មានញញើតដៃ ដែលមានកូនខ្មែរជាច្រើនរយ នាក់ធ្លាក់ចូលទៅក្នុងអន្ទាក់គ្រោះថ្នាក់ ដែលជា ចំណែកបង្កដល់អសន្តិសុខសង្គមផងនោះ ។ ដែល ជុំវិញបញ្ហាឧក្រិដ្ឋនានានោះ មានកូនខ្មែរប្រមាណ 1700នាក់ ត្រូវបញ្ជូនត្រឡប់ទៅកាន់ប្រទេស កម្ពុជា ដែលចំនួនភាគច្រើនបំផុតសុទ្ធតែជាកូន

(តទៅទំព័រទី០៩)


## ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
**Jeffrey N. Kale**
Attorney at Law



**ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ ជូនដល់សហគមន៍ខ្មែរជាង ២០ ឆ្នាំហើយ .**
**ការិយាល័យ"ច្បាប់ទូទៅ" ដែលមានជំនាញផ្លូវច្បាប់ដូចតទៅ :**

- គ្រោះថ្នាក់រថយន្ត
- បើកបរក្រោមឥទ្ធិពលញៀន ឬពុល
- មានរបួសនៅកន្លែងធ្វើការ
- ទិញលក់អចលនវត្ថុ
- ច្បាប់បើកក្រុមហ៊ុន
- ច្បាប់ឧក្រិដ្ឋកម្ម
- គ្រោះថ្នាក់ដោយរអិល ឬដួល
- រំលោភច្បាប់លើផ្លូវចរាចរ
- ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**
Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

| | |
|---|---|
| Car Accidents | Criminal Law |
| DUI/DWI | Slip & Fall Accidents |
| Workplace Injury | Traffic Violations |
| Real Estate | Collections |
| Corporate Law | |

**សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ នឹងតម្លៃគួរសម**
**អាចមានអ្នកបកប្រែជូនបាន**



# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300

សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាប" យើងធ្វើចុនពីដើមដល់ចប់បានយើង មានក្រុមទន្តបណ្ឌិត៤រូប ដែលមានជំនាញគ្រប់ជ្រុងជ្រោយនៃវិជ្ជាធ្វើធ្មេញ ។





**មណ្ឌលធ្មេញឯកទេស ខាងការទារលំអរ**

**ឯកទេសខាង**

- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅ ហ្វីឡាដែលហៀវតែមួយ ដែលមានបន្ទប់ពិសោធន៍ នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួស ដែលផលិតឡើងតាមគុណ ភាព ដែលលោកអ្នកចង់បាន ទាំងអស់សុទ្ធតែដំណើរ ការណ៍ដោយបច្ចេកទេសវិជ្ជា ជាន់ខ្ពស់ ហើយប្រើលំនាំ ប្រព័ន្ធ OSHA ជាក្បូន។

**ទន្តសាស្ត្រទូទៅ**

- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្ទិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- **-សំអាតធ្មេញឱ្យស្អាត:** ដោយធ្វើដោយឡេស័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

| | |
|---|---|
| ថ្ងៃ ច័ន្ទ | : 10am-6pm |
| ថ្ងៃ អង្គារ | : 10am-6pm |
| ថ្ងៃ ពុធ | : 10am-7pm. |
| ថ្ងៃ ព្រហស្បតិ៍ | : 10am-6pm |
| ថ្ងៃ សុក្រ | : 10am-6pm. |
| ថ្ងៃ សៅរ៍ | : 10am-7pm |

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

**ចុះថ្លៃ 10% ដល់អ្នកគ្មានប័ណ្ណសុខភាព**

**អាចធ្វើផែនការណ៍ចេញថ្លៃរាល់ខែ**

# ឆ្នាំថ្មី២០០៩ សម្រេចចិត្តថ្មី

**ដោយ : ពិន សំខុន**

•••លោកអ្នកអានជាទីមេត្រី ! យើងខ្ញុំដែលជាសហការី "ខ្មែរប៉ុស្តិ៍" មានសេចក្តីត្រេកអរជាពន្លឹកដោយនាឆ្នាំកន្លងទៅនេះ បានឃើញសហគមន៍យើងសម្តែងការពេញចិត្ត និងទទួលយកស្នាដៃកូនខ្មែរមួយនេះ ទៅអានតាមដាន ទាមទារយ៉ាងទៀតទាត់ ហើយផ្តល់ការលើកទឹកចិត្តមកវិញគួរឱ្យគោរពជាទីបំផុត។ ខ្លះបានសម្តែងថា "កាសែតនេះ ផ្តល់ព័តិមានបានច្រើនពីក្នុង និងក្រៅសហគមន៍ដោយក្លាហានមិនលំអៀង និងដោយត្រឹមត្រូវ" ខ្លះទៀតក៏ថា "តែបើប្តីខ្ញុំទៅយកកាសែតមិនទាន់គេ គាត់មួរម៉ៅក្នុងចិត្តណាស់ "។ ប្រៀបធៀបទៅឆ្នាំចាស់ ២០០៨ ពាក្យចាស់អម្បាមាណនេះ បានវាយតម្លៃឱ្យ "ខ្មែរប៉ុស្តិ៍" ថា យើងខ្ញុំបានសម្រេចនៅគោលដៅបំរើការអានរបស់លោកអ្នកថា "ខ្មែរប៉ុស្តិ៍" ជា "កាសែតខ្ញុំ" ដូចគ្នានឹងពាក្យថា "ធានាគារខ្ញុំ" "ផ្សារខ្ញុំ" ដូច្នេះដែរ ។ យើងបានប្រាថ្នាថា ឱ្យកាសែតមួយនេះនឹងក្លាយជា "កញ្ចក់អន្ទោលតាមប្រាណ" អាចឱ្យលោកអ្នកប្តូរគំនិតយោបល់កែប្រែលម្អរូបរាង្គកាយសហគមន៍ រូបរាង្គកាយក្រុមគ្រួសារ ឬក៏រូបរាង្គកាយខ្លួនឯងផ្ទាល់ឱ្យប្រសើរឡើងបានដោយចំណេះដឹង និងដោយសារតែកាសែតនេះអនុញ្ញាតឱ្យលោកអ្នកមើលខ្លួនឯងឃើញ ។

លោកអ្នកប្រាដកជាបានដឹងហើយថា ទូទៅសហគមន៍យើងនេះក្រណាស់ប្រមាណ៧០% រស់នៅក្រោមបន្ទាត់ក្រីក្រប្រមាណជិត៣០% រស់នៅក្នុងជីវភាពមធ្យម មានតែ១ ឬ២% ប៉ុណ្ណោះដែលរស់នៅធូរធារ។ នេះប្រាកដជាពុំមែនជាមោទនភាពរបស់យើងបានទេ។ តែពីលើនេះទៀតដោយរស់នៅគ្មានកញ្ចក់ឆ្លុះប្រាណ យើងពុំមើលឃើញថា "ភាពគ្មានចំណេះ" របស់យើងបានបំផ្លាញយើងប៉ុណ្ណោះនោះទេ ហើយយើងក៏គ្មានអ្វីនឹងប្រែប្តូរនោះឡើយដោយភាពអន្ធការនោះ ដូច្នេះជាអាទិ :

១-យើងមិនដឹងថា សហគមន៍មានប៉ុណ្ណោះ? លោក រឿម ឡុង អ្នកសេដ្ឋកិច្ចម្នាក់ អនុប្រធានសហគមន៍ខ្មែរ នៅហ្វីឡាដែលហ្វីយ៉ា បាននិយាយថា : ខ្មែរយើងការកូនចៅប្រមាណ២០នាក់ក្នុងមួយឆ្នាំ យកលុយទៅឱ្យសហគមន៍ផ្សេងដែលគេមានហាងទទួលភ្ញៀវប្រមាណ១៥០០០x ២០=១៣០,០០០ក្នុងមួយឆ្នាំៗចាយទៅក្នុងការជប់លៀងជួយទៅកម្ពុជាប្រមាណ៧០ដង ដែលប៉ាន់ប្រមាណថា ៣០,០០០ x ១០ = ៣០០,០០០ រីឯដំណើរយកលុយទៅចាយនៅកម្ពុជាប្រមាណ ១០០០នាក់ក្នុងមួយឆ្នាំ ដែលយកលុយទៅចាយជាមធ្យម៥០០០x១០០០=៥,០០០,០០០ ទាំងនេះពុំមានរាប់បញ្ចូលការចំណាយទៅផ្សារ ដែលសហគមន៍ផ្សេងពីខ្មែរ ពុំរាប់បញ្ចូលគ្រឿងស្រវឹង និងគ្រឿងជក់យ៉ាងទូលំទូលាយ ឬក៏ពីពិធីបុណ្យគ្រួសារ ដូចជាបង្កក់កូន បុណ្យខួបកំណើត ។ល។ សហគមន៍ខ្មែរ ប្រមាណជាង២៥,០០០នាក់ នៅហ្វីឡាដែលហ្វីយ៉ា បានបញ្ចេញប្រាក់នៅក្រៅសហគមន៍ប្រមាណ៦លានដុល្លារក្នុង១ឆ្នាំៗ ដែលប្រាក់ទាំងនោះ ពុំត្រឡប់មកជាប្រយោជន៍ឱ្យសហគមន៍ ឬក្រុមគ្រួសារឯងវិញទេ។

២-តើសហគមន៍យើងជួយគ្នាប៉ុណ្ណា? នៅក្នុងគ្រួសារខ្មែរយើងបានបាត់ទំនៀមទំលាបជួយគ្នាអស់ហើយ ដោយឪពុកម្តាយបោះបង់កូនចៅ ឬក៏កូនចៅបោះបង់ឪពុកម្តាយមានច្រើនសន្ធឹកសន្ធាប់ -លោកឈិន ទី គឺធ្វើការនៅ School districk បាននិយាយថា ក្មេងខ្មែរប្រមាណ៧០ % បានបោះបង់ការសិក្សានៅក៏រិតវិទ្យាល័យ(លើសពីក៏រិតរបស់តំបន់ដែលមាន៥៥%)-អ្នកមានកម្លាំងធ្វើការជាច្រើន នាឆ្នាំមុនៗ សប្បាយនឹងធ្វើការបានប្រាក់សុទ្ធ និងប្រាក់ជំនួយរដ្ឋថែមទៀត តើទៅថ្ងៃមុខនឹងមានលទ្ធផលនេះទៀត ដែរឬទេ? ពុំមាននរណាជួយតម្រែតម្រង់ឱ្យសហគមន៍មានការធានាដល់ជីវិតអនាគតរបស់ខ្លួនឯងនៅពេលឈឺថ្កាត់នៅពេលចូលនិវត្តន៍ -ចុះបញ្ញាវន្តខ្មែរទៅណាអស់ ? គឺគេចូលចិត្តទៅរវល់នឹងបញ្ហាស្រុកខ្មែរច្រើនជាងទីកន្លែងដែលខ្លួនរស់នៅ។ នៅមានច្រើនទៀតដូចជាខ្វះកន្លែងមើលកូនតូចៗនៅពេលម្តាយឪពុកទៅធ្វើការរកប្រាក់ចំណូល -ខ្វះជម្រកចាស់ៗដែលត្រូវរស់នៅដោយឯករាជ្យពុំចាំបាច់ពឹងកូនចៅ ឬពឹងវត្តអារាម -ភាពកក់ក្តៅរបស់ចាស់ៗខ្មែរទៅលើវត្តអារាមបានត្រូវយុវវ័យ ឬបញ្ញាវន្តច្រើនបានវាយតម្លៃថា "ទៅធ្វើបុណ្យមិនបានបុណ្យទេ" ពីព្រោះវត្តអារាមជាទូទៅពុំមានរចនាសម្ព័ន្ធ ឬទស្សនៈវិស័យជួយពុទ្ធសាសនិក នាក្នុងបច្ចុប្បន្នជាតិនេះវិញទេ។

៣- តើដឹងថា ខ្មែរគិតពីអនាគតខ្លួនឯងប៉ុណ្ណាទេ ? គិតពីអនាគត គេតែងនិយាយពីការរស់នៅបន្ទាប់ពីចូលនិវត្តន៍ ឬក៏ជីវភាពបន្ទាប់ពីមានគ្រួសារ ឬក៏ជីវភាពពេលមានកូនចៅ តើនឹងរស់នៅប្រសើរដែរឬទេ ? តែសហគមន៍ខ្មែរយើងរស់នៅ ដោយការសង្គ្រោះស្ទើរទាំងអស់ពុំមានផ្អែកទៅលើកម្លាំងខ្លួនឯងសុទ្ធសាធនោះទេ ។ តើនៅហ្វីឡាដែលហ្វីយ៉ានេះ មានប្រជាពលរដ្ឋប៉ុន្មាននាក់ ដែលមានគម្រោងសន្សំលុយសម្រាប់គ្រាក្រ តើខ្មែរប៉ុន្មាននាក់មានការធានាសុខភាពនៅពេលឈឺថ្កាត់ ? តើមានមនុស្សប៉ុន្មាននាក់ ដែលមានការធានាដល់អាយុជីវិត ដើម្បីសម្រួលជីវិតអ្នកនៅសល់ នៅពេលខ្លួនស្លាប់ ។

គ្រួសារខ្មែរ ដោយសារតែពុំមានទម្លាប់ធ្វើអ្វីមួយដោយមានគម្រោង ពុំមានទម្លាប់គិតពីអនាគតវែងឆ្ងាយ ក៏បណ្តោយខ្លួនឱ្យរស់នៅក្នុងចរន្ត "បញ្ញើក្អែក". ចរន្តនៃការគ្មានភាពពិត. ចរន្តដែលអំណោយផលនៃសហរដ្ឋអាមេរិក មិនបាន ។ ហេតុនេះហើយ បានជាភាពតស៊ូក្នុងជីវិតរបស់សមាជិកនៃសហគមន៍ខ្មែរ គឺខំរកបានមកយកទៅកំសាន្ត និងបំប៉នល្បែង ឬគ្រឿងស្រវឹងដើម្បីបំភ្លេចភាពនឿយណាយ. នៅសល់បន្តិចបន្តួចយកទៅបន្ទូរបរិយាកាសស្រុកខ្មែរ ដោយធ្វើនយោបាយ ធ្វើបុណ្យ ឬប្រព្រឹត្តអ្វី ដែលនៅសហរដ្ឋអាមេរិកពុំអាចធ្វើបាន. ខំរកលុយពេកទៅ រហូតដល់ភ្លេចរៀនសូត្រពីចំណេះនៃការរស់នៅលើទឹកដីនៃសហរដ្ឋអាមេរិក ធ្វើឱ្យវិបត្តិគ្រួសារគរដូចភ្នំ ទាល់តែអំណាចរដ្ឋធ្លាក់មកជាអាជ្ញាយ៉ាងតឹងតែង. ដោះស្រាយបញ្ហា ជីវិតដោយយកសីលធម៌ជាគោលនៃជីវិតទៅប្តូរនឹងប្រាក់ចំណូលសំខាន់ម្តងម្កាល... ។ល។

៤-តើមានបានដឹងទេថា ខ្មែរពុំបានដឹងពីយន្តការសំរាប់ព្យាបាលវិបត្តិសង្គមគ្រួសារនោះទេ ?

(តនៅទំព័រទី១០)


**BALDI FUNERAL HOME**

1331 S. Broad St.
Philadelphia, Pa 19147
Cell: 267-934-9888
Tel : 215-389-2414

សូមសួររកលោក សេខ ឬ Thomas

**ឈាបណកិច្ចតាមប្រពៃណី**

ឈាបណដ្ឋានមានផ្តល់ជូននូវក្តារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្តីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

**ពិធីបូជាសព**

"បាល់ឌី" ផ្តល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្តារមឈូសសំរាប់សពទន្ទឹមនោះ មានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិធាតុជាចុងបញ្ចប់។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។





(Locates in South Philly, convenience traffic, and free parking)

**Traditional Funeral**

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

**Cremation**

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# អ្នកស្រី អាំង ខេន ធ្វើការ៤៤ឆ្នាំ នៅវិទ្យុ V.O.A

●●●អ្នកស្រី អាំង ខេន គឺជាស្ត្រីខ្មែរដំបូងបង្អស់ ដែលបានចេញទៅអាមេរិក បំរើការងារក្នុងវិទ្យុផ្សាយសម្លេង V.O.A តាំងពីនៅក្រមុំអាយុ21ឆ្នាំ ហើយដែលនៅពេលនេះគាត់មានវ័យជាង60ឆ្នាំឬាយហើយ ។ អ្នកស្រីបានចេញទៅធ្វើការឱ្យវិទ្យុអាមេរិក (V.O.A) តាំងពីឆ្នាំ1962 មកម្លេះ តាមរយៈការប្រកាសជ្រើសរើសរបស់ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ។ សព្វថ្ងៃអ្នកស្រី អាំង ខេន បាននឹងកំពុងរស់នៅរដ្ឋ វីជីញ៉ា សហរដ្ឋអាមេរិកជាមួយនឹងប្តីរបស់គាត់ដែលជាពាណិជ្ជករព្រមទាំងកូនប្រុសទោលរបស់គាត់ ។

អ្នកស្រីអាំង ខេន មានស្រុកកំណើតក្នុងទីរួមខេត្តសៀមរាបជាកូនទោលក្នុងគ្រួសារជាគ្រូបង្រៀនទាំងឪពុកទាំងម្តាយ ។ នៅពេលគាត់មានអាយុ៥ឆ្នាំ ឪពុកម្តាយរបស់គាត់បានលែងលះគ្នា ហើយគាត់ត្រូវបានច្បាប់កាត់ឱ្យមករស់នៅជាមួយឪពុក និងត្រូវបានឪពុកយកមកឱ្យជីដូនចិញ្ចឹមបីបាច់ថែរក្សា ។ ដោយលើកឡើងពីក្មេងរហូតមកដល់ពេលធ្វើការនៅ V.O.A គាត់បានមានប្រសាសន៍ប្រាប់ដល់ទស្សនាវដ្តីខ្មែរអប្សរាតាមទូរស័ព្ទពីសហរដ្ឋអាមេរិកថា នៅពីក្មេងខ្ញុំត្រូវបានជីដូនឱ្យទៅរៀននៅសាលាវត្តដំណាក់ខេត្តសៀមរាប ។ ដោយសារតែក្មេងស្រី និងគ្រូបង្រៀនអក្សរជាព្រះសង្ឃខ្ញុំមិនត្រូវបានលោកសង្ឃព្រះនាម ឡាយ ចាប់ដៃសរសេរអក្សរដូចក្មេងប្រុសផ្សេងៗក្នុងថ្នាក់ទេ ។ បានន័យថា ខ្ញុំបានត្រឹមតែសរសេរអក្សរតាមការគូសបង្ហាញរបស់លោកគ្រូជាព្រះសង្ឃអង្គនោះ តែប៉ុណ្ណោះជាហេតុធ្វើឱ្យខ្ញុំសរសេរអក្សរពុំបានល្អដូចសិស្សក្នុងថ្នាក់ឯទៀតជាមួយគ្នាទេ តែយ៉ាងណាខ្ញុំមានការសប្បាយចិត្ត ដោយលោកគ្រូបានទុកម៉ោងឱ្យខ្ញុំ ងោកង៉ក់ក្នុងម៉ោងរៀនបាន ដោយពុំត្រូវរំពាត់ដូចក្មេងដទៃ ហើយពេលកូនសិស្សចេញលេង គឺជាឱកាសដែលលោកគ្រូចាប់ផ្តើមបង្រៀនខ្ញុំ គឺហាក់ដូចជាខ្ញុំនេះបានរៀនជាមួយគ្រូមួយទល់មួយនឹងមួយដូច្នេះដែរ ។

អ្នកស្រីនិយាយថា ក្នុងពេលសិក្សានៅ


អ្នកស្រី អាំង ខេន


អគារ V. O.A

សាលាវត្តឆ្នាំណា ក៏ដូចឆ្នាំណាដែរ ខ្ញុំតែងតែរៀនត្រួតថ្នាក់ រហូតដល់ពេលដែលខ្ញុំធំដឹងក្តី ហើយនៅខេត្តសៀមរាបបានបង្កើតអនុវិទ្យាល័យសូរ្យវ័ន្តទើបខ្ញុំអាចរៀនបានទាន់នឹងគេ នឹងបានប្រលងជាប់សញ្ញាប័ត្រដូចគេដូចឯង ដោយគ្មាននរណាជួយទាំងអស់ ។ ហើយក្នុងពេលដែលខ្ញុំរៀនសាលាវត្តក្រៅអំពីអក្សរសាស្ត្រខ្មែរ និងភាសាបាលីដែលបង្រៀនដោយព្រះសង្ឃនោះ គឺខ្ញុំបានឆ្លៀតរៀនភាសាបារាំងជាមួយនឹងឪពុកមារបស់ខ្ញុំដែលគាត់ចេះភាសាបារាំងយ៉ាងបង្គួរ ។

អ្នកស្រីបន្តថា ក្រោយពេលដែលឪពុករបស់ខ្ញុំបានផ្ទេរការងារមកភ្នំពេញ ខ្ញុំក៏ត្រូវផ្ទេរការសិក្សាមកតាមគាត់ដែរ ។ ពេលមកភ្នំពេញដំបូងខ្ញុំមានការចម្លែកក្នុងចិត្តមែនទែន ដោយសារទីក្រុងនេះមានមនុស្សម្នាច្រើនផ្លូវធំៗ និងមានទីកន្លែងខ្លះ មិនស្អាតមិនដូចសៀមរាបនាពេលនោះទេ ពោលគឺខ្ញុំធ្លាប់តែឃើញក្រុងសៀមរាបនូវបរិស្ថានល្អស្អាត, ទឹកស្ទឹងហូរវែងអន្លាយ ពីភ្នំគូលែនធ្លាក់ដល់ទន្លេសាប គឺស្អាតមែនទែនជាហេតុធ្វើឱ្យខ្ញុំមានការពិបាករស់នៅមែនទែន។ ខ្ញុំបានចូលទៅរៀននៅអនុវិទ្យាល័យនារី (សាលាបឋមសិក្សានរោត្តមសព្វថ្ងៃ) ។ ដោយសារកាលនោះ ប្រទេសខ្មែរយើងពុំសូវមានធនធានមនុស្សផ្នែកខាងភាសាអង់គ្លេស ម្លោះហើយសាលារបស់ខ្ញុំបានយកគ្រូជនជាតិបារាំង មកបង្រៀនភាសាអង់គ្លេស ហើយក្រោយមកទៀត ទើបមានអ្នកគ្រូជនជាតិខ្មែរម្នាក់មកបង្រៀន គឺអ្នកគ្រូ អៀង ធីរិទ្ធ ប្រពន្ធរបស់លោក អៀង សារី ដែលជាអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ។ នៅពេលកំពុងសិក្សាក្នុងអនុវិទ្យាល័យនោះ ខ្ញុំបានទទួលនូវព័ត៌មានពី USIF របស់អាមេរិកប្រកាសជ្រើសរើសសិស្សខ្មែរ ដើម្បីផ្តល់អាហារូបករណ៍ទៅសិក្សានៅសហរដ្ឋអាមេរិក រយៈពេល1ឆ្នាំ នាឆ្នាំ 1959 ដោយមហាសេដ្ឋីជនជាតិអាមេរិក ម្នាក់ឈ្មោះ កាឡាទី ធ្វើការជ្រើសរើសសិស្សមកពីបណ្តាប្រទេសជាច្រើន ក្នុងពិភពលោកមានដូចជាប្រទេសខ្មែរ,លាវ,វៀតណាម,ម៉ាឡេស៊ី សាំងហ្គាពួរ , ហ្វីលីពីន , ប្រេស៊ីល , អេក្វាទ័រ, អាហ្សង់ទីន ...។ ខ្ញុំបានដាក់ពាក្យប្រលង ហើយបានជាប់ក្នុងការជ្រើសរើសនោះ ។

បន្ទាប់ពីបញ្ចប់ការសិក្សាតាមរយៈអាហារូបករណ៍រយៈ ពេល1ឆ្នាំនោះអ្នកស្រី អាំង ខេន ក៏បានវិលត្រឡប់មកពីសហរដ្ឋអាមេរិកវិញ នាឆ្នាំ 1960 ហើយបានចូលធ្វើការនៅក្រសួងនេសាទ មានតួនាទីជាលេខារបស់លោក ដោត សារឿន មានភារៈជាអ្នកកាត់ព័ត៌មានពីកាសែតនានាដែលចេញផ្សាយប្រចាំថ្ងៃ និងក៏ជាអ្នកធ្វើនូវរបាយការណ៍ស្តីអំពីចំណូលពីឡូត៍នេសាទផងដែរ ។ ក្រោយពីធ្វើការនៅក្រសួងនេសាទបានមួយឆ្នាំ ស្ថានទូតអាមេរិកក៏បានចេញសេចក្តីប្រកាសជ្រើសរើសអ្នកដែលចេះភាសាខ្មែរ និងភាសាអង់គ្លេសទៅធ្វើការនៅ V.O.A ។ បន្ទាប់ពីបានឃើញសេចក្តី ប្រកាសនោះអ្នកស្រី អាំង ខេន ក៏បានសុំការអនុញ្ញាតិពីឪពុករបស់គាត់ដាក់ពាក្យប្រលងធ្វើការនៅ V.O.A ។ អ្នកស្រី អាំង ខេន និយាយថា ពេលនោះ ឪពុករបស់ខ្ញុំគាត់សម្តែងនូវការភ្ញាក់ផ្អើលជាខ្លាំង និងបានសួរនាំខ្ញុំថា តើហេតុដូចម្តេចក៏សុំទៅធ្វើការនៅវិទ្យុអាមេរិក ព្រោះអ្នកមុនៗគេធ្វើការនៅទីនោះមិនបានប៉ុន្មានផងក៏ឈប់ទៅវិញ ហើយគេសុទ្ធតែប្រុសៗទៅទៀត ហើយកូនជាស្រីម្តេចធ្វើការនៅទីនោះបានទៅ ? ពេលនោះខ្ញុំបាននិយាយប្រាប់ឪពុកខ្ញុំថា មិនអីទេ ខ្ញុំអាចធ្វើការងារក្នុង V.O.A បាន ។ អ្នកស្រី អាំង ខេន បានមកធ្វើតេស្តសាកសម្លេង និងបកប្រែភាសាអង់គ្លេសមកខ្មែរ និងពីខ្មែរមកអង់គ្លេសវិញ រួចហើយក៏ជាប់បានទៅធ្វើការនៅ V.O.A ។ អ្នកស្រីបាន

(តទៅទំព័រទី០៩)

NEW GOLDEN PALACE RESTAURANT
801-21 Washington Ave.
Phone: 215-627-2822
Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm
Authentic Chinese & Vietnamese Cuisine
Very Delicious and Nutritious

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ
**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)
**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%**លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon

# ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
## Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
**(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ធាំង ឆារសាច់គោ
- មីកន្ធាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង



**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉ុងបាតេ ឬសាច់គោអាំង
- ខគោ នំប៉ុង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# ប្រទេសថៃប្រើនាយករដ្ឋមន្ត្រី៣ក្នុង១ឆ្នាំ

**ដោយ : ម៉ម យិន**

ចាប់តាំងពីខែធ្នូ ឆ្នាំ២០០៧ ដល់ខែធ្នូ ឆ្នាំ២០០៨ ប្រទេសថៃ បានគ្រប់គ្រងដឹកនាំដោយនាយករដ្ឋមន្ត្រីចំនួន៣រូបគឺ : នាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនណារ៉ាវេត ប្រធានគណបក្សផ្លាំងប្រជាជន (កម្លាំងប្រជាជន) ទទួលជ័យជំនះក្នុងការបោះឆ្នោតឆ្នាំ២០០៧ បានឡើងធ្វើជានាយករដ្ឋមន្ត្រី។

ដោយសារមានកំហុសក្នុងការគ្រប់គ្រងក៏ត្រូវបានតុលាការធម្មនុញ្ញកាត់សេចក្តីដកចេញពីតុលាការ ។

លោកចៅក្រម ស៊ុមឆាយ វង់សុវត្ថិ ត្រូវបានជ្រើសរើសឱ្យធ្វើជានាយករដ្ឋមន្ត្រីថៃទី២ បន្តបន្ទាប់មកត្រូវបានតុលាការកាត់ក្តីដកហូតតំណែងម្តងទៀត កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៨ ។

ដើម្បីរកដំណោះស្រាយបញ្ហាវិបត្តិនយោ-បាយប្រទេសថៃ ដែលបានកើតមកជាច្រើនឆ្នាំមកហើយនេះ ធ្វើឱ្យក្រុមបញ្ញាវន្តសំខាន់ៗទាំងចាស់ទាំងក្មេងនាំគ្នាបញ្ចេញមតិក្រោយពីបានប្រជុំពិភាក្សាគ្នាយ៉ាងល្អិតល្អន់ រកច្រកចេញឱ្យបានរួចពីវិបត្តិដ៏យូរមកនេះ ដោយយកមតិភាគច្រើនឱ្យដឹងថា ត្រូវតែជ្រើសរើសយកប្រធានគណបក្សប្រជាធិប៉ាត់ (ប្រជាធិបតេយ្យ) ដែលជាគណបក្សប្រឆាំងមានចំនួនអាសនៈលំដាប់ថ្នាក់ទី២ បានទទួលតំណែងជានាយករដ្ឋមន្ត្រីថ្មីតទៅ។

**នាយករដ្ឋមន្ត្រីថៃថ្មី បានចូលកាន់តំណែងហើយ :**

ទោះបីមានការបះបោរប្រឆាំងជំទាស់ពីគណបក្ស ដែលត្រូវដកចេញពីអំណាចយ៉ាងណាក៏ដោយ ការជ្រើសរើសនាយករដ្ឋមន្ត្រីថ្មី បានសម្រេចកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ គឺលោក អភិសិទ្ធ វីជ្ជាជីវៈ ជាប្រធានគណបក្សប្រជាធិបតេយ្យ ត្រូវបានអង្គប្រជុំរដ្ឋសភាជាតិថៃ បោះឆ្នោតដោយមតិភាគច្រើន ឱ្យរៀបចំរដ្ឋាភិបាលមួយ សំរាប់ដោះស្រាយវិបត្តិទាំងអស់ ដែលមានកន្លងមក ។

ភាពស្ងប់ស្ងាត់ខាងក្រុមប្រជុំមហាជនអាវលឿង ដែលមានឈ្មោះថា "ក្រុមសម្ព័ន្ធមិត្តប្រជាជន ដើម្បីលទ្ធិប្រជាធិបតេយ្យ បានស្ថិតក្នុងបរិយាកាសល្អប្រសើរ ដើម្បីជួយផ្តល់មតិល្អៗ


លោក ថាក់ស៊ីន អតីតនាយករដ្ឋមន្ត្រីសៀម


អាប់ហ៊ីស៊ីត វិជ្ជាជីវ៉ា នាយករដ្ឋមន្ត្រីសៀមថ្មី


ក្រុមប្រឆាំងអាវលឿង

ជាជំនួយដល់លោកនាយករដ្ឋមន្ត្រីថ្មី ។

ផ្ទុយទៅវិញ ខាងក្រុមប្រឆាំងមួយទៀតមានអាវពណ៌ក្រហមឆ្អៅ បានប្រជុំមហាជនយ៉ាងតក្រឹកតគ្រេង ប្រឆាំងជំទាស់នឹងការតែងតាំងនាយករដ្ឋមន្ត្រីថ្មីនេះម្តងវិញ ដោយចេញមកពីគណបក្សថ្មីមួយឈ្មោះ ភឿថៃ (ដើម្បីជាតិថៃ) ជាក្រុមនិយមលោក ថាក់ស៊ិន ។

លុះមកដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨ ដែលជាថ្ងៃកំណត់សំរាប់ថ្លែងគោលការណ៍នយោបាយរបស់រដ្ឋាភិបាលថ្មី នៅក្នុងសភាជាតិ សុំសេចក្តីទុកចិត្តពីរដ្ឋសភាជាតិ ថ្ងៃនោះក្រុមប្រឆាំងពាក់អាវក្រហមនាំគ្នាទៅរាំងផ្លូវបិតទ្វារច្រកចូលមន្ទីររដ្ឋសភាជាតិ ក្នុងគោលបំណងបំផ្លាញការប្រជុំថ្លែងនយោបាយរបស់រដ្ឋាភិបាលថ្មី ឱ្យទទួលបរាជ័យ ហើយមិនអាចឱ្យរដ្ឋាភិបាលថ្មី មានលទ្ធភាពដំណើរការទៅមុនបានឡើយ ។

**បរាជ័យក្រុមអាវក្រហម :**

ការប្រជុំមហាជនក្រុមអាវក្រហម ដើម្បីបិទផ្លូវច្រកទ្វារចូលរដ្ឋសភាជាតិ បានប្រព្រឹត្តទៅយ៉ាងក្តៅគគុក និងប្រកបដោយអំពើហិង្សាខ្លះទៀតផង ដែលមតិខ្លះយល់ថា នឹងអាចបណ្តាលឱ្យមានការរំលាយរដ្ឋសភា ឬបញ្ឈប់សកម្មភាពរបស់រដ្ឋាភិបាលថ្មីនេះបានទៀតផង។ ពីព្រោះក្រុមអាវក្រហមបានទទួលការលើកទឹកចិត្តពីអតីតនាយកមន្ត្រីទាំង៣រូប ដែលបានធ្លាប់កាន់អំណាច ។

នៅក្នុងកាលៈទេសៈដ៏ច្រូលច្របល់ និងគ្រោះថ្នាក់នេះ នាយករដ្ឋមន្ត្រី គណរដ្ឋមន្ត្រី ព្រមទាំងសមាជិកតំណាងរាស្ត្រគ្រប់គណបក្ស ដែលបានចូលរួមគ្នាបង្កើតរដ្ឋាភិបាលថ្មី បានប្រជុំគ្នារិះរកយុទ្ធវិធី ដើម្បីធ្វើយ៉ាងណាឱ្យការប្រជុំថ្លែងគោលការណ៍នយោបាយនេះ ឱ្យបានប្រព្រឹត្តទៅដោយជោគជ័យ ។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨ កិច្ចប្រជុំត្រូវបានផ្អាកលើកម៉ោងជាច្រើនដង ។

នៅថ្ងៃទី២៩ ធ្នូ ស្ថានការណ៍នៅតែតានតឹងដដែល ហើយការប្រជុំ ត្រូវបានផ្អាកម្តងទៀត។ លុះមកដល់ថ្ងៃទី៣០ ខែធ្នូ គឺជាថ្ងៃគំរប់ទី៣ នាយករដ្ឋមន្ត្រីត្រូវតែខិតខំពុះពារទំលាយការប្រឆាំងរបស់ក្រុមអាវក្រហមឱ្យបានជាដាច់ខាត ដោយត្រូវប្តូរកន្លែងសំរាប់ប្រជុំ ទើបអាចធ្វើទៅបាន ។

ដូច្នេះ កន្លែងថ្មីត្រូវកំណត់យកនៅក្នុងទីស្នាក់ការនៃក្រសួងការបរទេស ដែលអាចផ្តល់លទ្ធភាពប្រជុំថ្លែងគោលការណ៍នយោបាយបាន ។

បន្ទាប់ពីបានថ្លែងនយោបាយចំពោះមុខសមាជិកសភាជាតិចប់សព្វគ្រប់ហើយ លោកនាយករដ្ឋមន្ត្រីអភិសិទ្ធ វិជ្ជាជីវៈ បានបើកប្រជុំពិសេសនៃគណរដ្ឋមន្ត្រី ដើម្បីចាប់ផ្តើមលើកយកបញ្ហាធំៗ ជាពិសេស បញ្ហាសេដ្ឋកិច្ច យកមកពិភាក្សារកដំណោះស្រាយឱ្យទាន់ពេលវេលា រួមទាំងបញ្ហាខាងសង្គមកិច្ចមួយចំនួនទៀត ដែលប្រជាពលរដ្ឋថៃ កំពុងជួបប្រទះ ។

សរុបសេចក្តីទៅក្រុមអាវក្រហម ជាក្រុមនិយមលោក ថាក់ស៊ិន ដែលមានគោលដៅ

(តទៅទំព័រទី២១)

The Khmer Post Directory
East Coast Publication
Regional Editor : Pin Samkhon
Email : pinsamkhon@gmail.com
Writers : Mam Yin
Kim Phean
Im Loeurm
Chhan Young
Advertising
Marketing/Advertising
Manager: Sabane Thach
Phone : 267-253-3947
Email : sabane.thach@gmail.com
West Coast Publication
RegionalEditor : Sovannara Meach
Writers : Kim Saroeurn
Ra Neat
Sophea Rith
Mey Sampos
Chan Kosal
Sovann Rith
Phone: (562) 313-2129
Email: sovannara04@yahoo.com

ខ្មែរប៉ុស្តិ៍មានសេចក្តីរីករាយ និងណែនាំដល់សហគមន៍ខ្មែរ




ឱសថស្ថានយើងនឹងជួយលោកអ្នកអំពីតម្លៃថ្នាំ ជាពិសេសដល់គ្រួសារដែលមានប្រាក់ចំណូលតិច

ឱសថស្ថានយើងខ្ញុំនឹងទូរស័ព្ទ ហើយធ្វើការជាមួយវេជ្ជបណ្ឌិត នឹងក្រុមហ៊ុនធានារ៉ាប់រងសុខភាព លោកអ្នកនឹងទទួលបានថ្នាំរបស់លោកអ្នកជាប្រាកដ

ឱសថស្ថាន Washington បានជួយអ្នកជំងឺរាប់ពាន់នាក់ នៅក្នុងសហគមន៍ ស្រាយបញ្ហាស្មុគស្មាញ ដើម្បីឱ្យបានឱសថដែលអ្នកទាំងនោះត្រូវការ ។

និយាយនិងពន្យល់អំពីថ្នាំ ជាភាសាខ្មែរ

លឿនអស្ចារ្យ :
ចាំ ១០ នាទី ឬយកទៅឱ្យដល់ផ្ទះ

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

# ស្ត្រីខ្មែរម្នាក់ស្លាប់ក្នុងភ្លើងឆេះផ្ទះ

**ដោយ : អ៊ុម លឿម**

០០០ស្ត្រីខ្មែរ-អាមេរិកាំងម្នាក់វ័យ២៨ឆ្នាំ ឈ្មោះ សាំង គីមទួន បានស្លាប់បាត់បង់ជីវិតនៅឯមន្ទីរពេទ្យរដ្ឋមួយកន្លែង ក្នុងទីក្រុងហ្វីឡាដែលហ្វៀខាងត្បូង កាលពីថ្ងៃច័ន្ទ ទី១៥ ខែធ្នូ ឆ្នាំ ២០០៨ កន្លងមកនេះ បន្ទាប់ពីនាងបានទទួលរងនូវការស្រូបផ្សែងភ្លើង ដោយសារឧប្បទ្ទវហេតុ ភ្លើងឆេះផ្ទះ កាលពីថ្ងៃអាទិត្យ ទី១៤ ធ្នូ កន្លងមកនេះ ។

ហេតុការណ៍ភ្លើងឆេះផ្ទះដ៏គួរឱ្យរន្ធត់នេះ បានកើតនៅចំពាក់កណ្តាលប្លុក១៦/១៧ លើផងវិថី Chadwick ក្នុងតំបន់ហ្វីឡាដែលហ្វៀ ខាងត្បូង ។

អ្នកបានឃើញហេតុការណ៍ផ្ទាល់ផ្នែកម្នាក់ ដែលមានលំនៅដ្ឋានក្បែរទីកើតហេតុនោះ បានប្រាប់ខ្មែរប៉ុស្តិ៍ នាថ្ងៃនោះថា : ប្រមាណជាម៉ោង ១១ព្រឹក គាត់បានឃើញផ្សែងភ្លើងហុចចេញពីបង្អួចចំម៉ាស៊ីនត្រជាក់ នៅក្នុងបន្ទប់ទទួលភ្ញៀវ ( Living room ) លុះបន្តិចក្រោយមកឃើញ មានផ្ទះផ្នែកខ្លះនៃកញ្ចក់បង្អួចនៅចាប់នឹងម៉ាស៊ីនត្រជាក់នោះ ហើយលោកបានព្យាយាមធាក់ទំលាយទ្វារ ដើម្បីចូលទៅជួយដែរ តែពុំអាចបើកទ្វារចូលរួច ក្រៅពីឈរមើលដោយក្តីតក់ស្លុត និងអន្ទះសាតែប៉ុណ្ណោះ ។

សូមជម្រាបថា ដោយសារតែមានការធ្វើអន្ត-រាគមន៍ពីក្រុមអ្នកពន្លត់អគ្គីភ័យទាន់ពេលវេលា ទើបមិនបណ្តាលឱ្យលំនៅដ្ឋាននោះ មានការឆេះខូចខាតអស់ទាំងស្រុងនោះឡើយ ដោយឆេះ និងខូចខាតមួយអន្លើនៅបន្ទប់ទទួលភ្ញៀវតែប៉ុណ្ណោះ ហើយជនរងគ្រោះ ដែលបានបាត់បង់ជីវិតនោះ ក៏ពុំបានទទួលរងនូវការឆេះភ្លើងដែរ ។

អ្នកនាង សាំង គីមទួន បានលាចាកលោកនេះទៅដោយបានបន្សល់ទុកនូវកូនប្រុសជាទីស្រឡាញ់ម្នាក់ អាយុ៧ឆ្នាំ ព្រមទាំងបានបន្សល់ទុកនូវស្នាមអនុស្សាវរីយ៍ជាច្រើនដល់ក្រុមគ្រួសារញាតិមិត្តជិតឆ្ងាយ និងជាពិសេស ពីសំណាក់ឪពុកម្តាយរបស់នាង ដែលអ្នកផងតែងតែមានការគោរពរាប់អានយ៉ាងច្រើន ។

លោក នួន សុផល ជាឪពុកជនរងគ្រោះ និងអាចារ្យប្រចាំវត្ត " ព្រះពុទ្ធប្រទានពរ" ផងនោះ បានសំដែងនូវភាពសោកស្តាយយ៉ាងខ្លាំង ចំពោះការបាត់បង់កូនស្រីដ៏គួរឱ្យស្រឡាញ់របស់លោក។ ចំណែកឯអ្នកស្រី ស៊ីវ គីមជន ដែលអ្នកផងស្គាល់ឈ្មោះក្រៅថា " ម៉ាក់អាចេក " និងជាម្តាយរបស់ជនរងគ្រោះ បានរៀបរាប់ប្រាប់ខ្មែរប៉ុស្តិ៍ នាថ្ងៃកើតហេតុ ទាំងទឹកមុខស្រពាប់ស្រពោនថា : នៅពេលព្រឹកប្រមាណជាម៉ោង១០:៣០នាទី អ្នកស្រីបានចៀនសាច់មាន់ ដើម្បីយកទៅវត្ត ប៉ុន្តែដោយសារតែប្រញាប់ប្រញាល់ពេក ក្រោយពីស្រង់សាច់មាន់ចេញពីខ្ទះ ហើយប្រហែលជាភ្លេចបិទភ្លើង ទើបបណ្តាលឱ្យកើតហេតុបែបនេះ។ ប៉ុន្តែ អ្នកស្រីហាក់មានការស្រពិចស្រពិល និងមានការស្ទាក់ស្ទើរក្នុងការបកស្រាយចំពោះហេតុការណ៍នោះ ។

រហូតមកដល់ពេលនេះ ខ្មែរប៉ុស្តិ៍ នៅពុំទាន់បានទទួលដំណឹងពីក្រុមជំនាញអំពីមូលហេតុច្បាស់លាស់នៃអព្ភូតហេតុអគ្គីភ័យប្រល័យជីវិតមនុស្សនេះនៅឡើយទេ ។ ប៉ុន្តែ បើផ្អែកតាមប្រភពក្រៅផ្លូវការ និងមានការតំណាលដូចគ្នា ពីសំណាក់អ្នកឃើញហេតុការណ៍ បានឱ្យដឹងថា ភ្លើងបានឆេះឆាប់ជាដំបូងផ្តើមចេញពីបន្ទប់ចំអិនម្ហូបអាហារ ដែលជាកន្លែងអ្នកស្រី ស៊ីវ គីមជន បានចំអិនម្ហូបសម្រាប់យកទៅវត្ត ។

សពអ្នកនាង សាំង គីមទួន ត្រូវបានបូជានៅរសៀលថ្ងៃសៅរ៍ ទី២០ ខែធ្នូ កន្លងមកនេះ ដោយមានអ្នកចូលរួមដង្ហែរ និងកាន់ទុក្ខយ៉ាងច្រើនសន្ធឹកសន្ធាប់ និងម្នាក់ៗបានសម្តែងនូវក្តីអាណិតស្រណោះអាឡោះអាល័យយ៉ាងខ្លាំង ចំពោះមរណភាពរបស់នាង ។

គួររំលឹកផងដែរថា : កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ ក៏ធ្លាប់កើតមានករណីអគ្គីភ័យប្រល័យជីវិតមនុស្សម្នាក់ផងដែរ ដោយជនរងគ្រោះមានឈ្មោះ ហុង សុម៉ាលី ភេទស្រី អាយុ ២៥ឆ្នាំ មានទីលំនៅក្នុងតំបន់ហ្វីឡាដែលហ្វៀខាងជើង ។ ក្នុងព្រឹត្តិ ការណ៍នោះ នាង សុម៉ាលី បានស្លាប់ភ្លាមៗនៅ កន្លែងកើតហេតុ ដោយបានបន្សល់ទុកនូវកូនអាយុ៣ខែ ព្រមទាំងមិត្តប្រុសជាទីស្រឡាញ់ របស់នាង ៕

**អ៊ុម លឿម**

## កាសែតខ្មែរប៉ុស្តិ៍ នៅ " រ៉ូដអាយឡែន "

❖❖❖លោកអ្នកអាន "ខ្មែរប៉ុស្តិ៍" នៅរដ្ឋអាឡិន អាចអញ្ជើញរកកាសែតរបស់លោកអ្នកបាន នៅ ប្រូវិដិន តាមហាងពាណិជ្ជកម្មដូចតទៅ:

1- ASIAN STAR MARKET
618 ELMWOOD AVENUE
PROVIDENCE RI 02907

2- VIDEO CHHAY SAVANN
384 ELMWOOD AVENUE
PROVIDENCE, RI 02907
Phone :(401)588 9306

3- FRIENDSHIP MARKET
187 MESER STREET
PROVIDENCE, RI 02907
Phone : (401) 274 3744

4- KHMER WORLD VIDEO (KW)
310 RESERVOIR AVENUE
PROViDENCE, RI 02907
Phone : 401- 467 5900

តម្លៃផលិតកាសែត នឹងផ្ញើបានកើនឡើងយ៉ាងខ្ពស់ ហេតុនេះ សូមលោកអ្នកអានមេត្តាអធ្យាស្រ័យចំពោះការដាក់តម្លៃ៥០សេន ក្នុងការជាវកាសែតមួយច្បាប់ ចាប់ពីពេលនេះទៅ ។ ទីចាត់ការខ្មែរប៉ុស្តិ៍ ៕







# អ្នករកស៊ីទិញដី និងផ្ទះកំពុងវិណ្ណ.ក

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : គីម សារឿន**

•••ខណៈពេលដែលប្រជាពលរដ្ឋកំពុងតែផ្អើលភ្លុកទឹក ភ្លុកដីនាំគ្នាទិញ-លក់ផ្ទះ និងដីធ្លីទុកសំរាប់លក់ដើម្បីយកចំណេញនោះ ស្រាប់តែវិបត្តិហិរញ្ញវត្ថុពិភពលោកបានផ្ទុះឡើង បានធ្វើឱ្យប្រទេសជុំវិញពិភពលោកទទួលរងផលប៉ះពាល់ស្មើរគ្រប់គ្នា ។

ដោយឡែកនៅប្រទេសកម្ពុជា ដែលអ្នកវិនិយោគទុនមកពីបរទេសមករកស៊ីច្រើន ហើយបានសង់ផ្ទះល្វែង អគារ និងទិញដីទុកចំណេញ បានផ្អាកការរកស៊ីរបស់ខ្លួនយ៉ាងតក់ក្រហល់ ធ្វើឱ្យប្រជាពលរដ្ឋខ្មែរមួយចំនួន ដែលរកស៊ីរបរនេះធ្លាក់ថ្លើមក្តុក រកតែស្រែកយំមិនចេញ ពីព្រោះពួកគាត់ខ្លះខ្ចីលុយពីធនាគារមកទិញដី ។

ក្រុមហ៊ុនរកស៊ីអចលនទ្រព្យ និងដីធ្លី បាននិយាយថា សព្វថ្ងៃនេះ តំលៃផ្ទះល្វែង វីឡា និងដីទាំងនៅទីក្រុង និងជនបទ បានធ្លាក់ថ្លៃពី20ទៅ40% ខណៈពេលដែលវិបត្តិហិរញ្ញវត្ថុទីផ្សារពិភពលោកវាយលុករយៈពេលប៉ុន្មានខែនេះ ។ សព្វថ្ងៃនេះ អ្នករកស៊ីដីធ្លី និងសំណង់តូចធំដែលភាគច្រើនមកពីបរទេស បានផ្អាកការងាររបស់ខ្លួន ហើយខ្លះក៏វិលត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញតែម្តង ។

លោក ឡុង មាស អ្នករកស៊ីទិញ និងលក់ផ្ទះនៅក្រុងភ្នំពេញ បានឱ្យដឹងថា វិបត្តិហិរញ្ញវត្ថុពិភពលោកបានធ្វើឱ្យសំណង់របស់គាត់នៅទ្រឹងគ្មានម៉ូយទិញ សូម្បីតែម្នាក់ក៏គ្មានដែរ ។ កន្លងមកលោកធ្លាប់នាំភ្ញៀវមកពីប្រទេសកូរ៉េ និងម៉ាឡេស៊ីមកទិញដី ដើម្បីអភិវឌ្ឍន៍សំណង់នៅតំបន់មួយចំនួននោះ ឥឡូវពួកគេក៏ផ្អាកការងាររកស៊ីដែរ ពីព្រោះខ្លាចខាត និងគ្មានលុយសំរាប់បង្វិលដំណើរការផងដែរ ។

លោក សេង សុភ័ក្រ្ត ប្រធាននាយកដ្ឋានវាយតំលៃអចលនទ្រព្យក្រុមហ៊ុនស៊ីភីអិល ខេមបូឌា



ដីប្រកាសលក់ ដែលគ្មានមោខឆេខ



មោខឆេខផ្ទះមានតម្លៃទ្រឹខ

ប្រេភើធី លីមីតធីត បានឱ្យដឹងថា តំលៃដីតាំងពីមុន និងក្រោយបោះឆ្នោត គឺនៅទ្រឹងទាំងនៅទីក្រុង និងជនបទ ប៉ុន្តែនៅទីក្រុងភ្នំពេញមានហាងឆេងបន្តិច ពីព្រោះមានគេត្រូវការជួល និងទិញខ្លះដែរ ។

ចំណែកលោក ចាប សុថារិទ្ធ ប្រធានប្រតិបត្តិការវិទ្យាស្ថានដើម្បីសន្តិភាព បានបញ្ជាក់ថា ហាងឆេងដីភាគច្រើនដែលមានតំលៃនោះ គឺភ្ញៀវមកពីកូរ៉េ ចិន ហុងកុង ម៉ាឡេស៊ី សាំងហ្គាពួរ និងខ្មែរនៅក្រៅប្រទេសមួយចំនួនទៀត ។ ប៉ុន្តែដល់ពេលមានវិបត្តិបែបនេះ ពួកគេក៏ផ្អាកការរកស៊ីដោយសារគេខ្វះខាតលុយ និងអាចថាមកពីបញ្ហាសង្គ្រាមចិត្តសាស្ត្រផងក៏មិនដឹង គឺគេនៅរង់ចាំសភាពការណ៍សិន ។

លោក ចាប សុថារិទ្ធ បន្តថា បើតាមការសង្កេត គឺតម្លៃអចលនទ្រព្យបានធ្លាក់ថ្លៃតាំងពីមុនពេលបោះឆ្នោតមកម្ល៉េះ ហើយវាទើបតែល្បីសុសសាយខ្លាំងពេលមានវិបត្តិសេដ្ឋកិច្ចទីផ្សារពិភពលោក ធ្វើឱ្យមនុស្សក្នុងប្រទេសយើងភ្ញាក់ផ្អើលរឿងនេះ ។

អ្នកសេដ្ឋកិច្ចនៅកម្ពុជា លោក កង ច័ន្ទតារ៉ាវ័ត្ត នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាដើម្បីអភិវឌ្ឍន៍ បានឱ្យដឹងថា សំណង់សំខាន់ៗនៅប្លុកប៊ូឌិងមណ្ឌលកំសាន្ត ទីផ្សារទំនើប និងអគារ42ជាន់ ដែលបានសាងសង់ប្រមាណជិតពាក់កណ្តាល ហើយ ក៏បានផ្អាកការងាររបស់ខ្លួនដែរ ។ នេះជារឿងមួយគួរឱ្យសោកស្តាយខ្លាំងណាស់ ដែលធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចយ៉ាងខ្លាំង ។

លោក កង ច័ន្ទតារ៉ាវ័ត្ត បញ្ជាក់ថា ដីនៅទីក្រុងកាលពីមុនមួយម៉ែត្រការ៉េតម្លៃ1500ដុល្លារ ឥឡូវសល់តែមួយម៉ែត្រការ៉េត្រឹមតែ200ដុល្លារប៉ុណ្ណោះ ។ ដី ឬផ្ទះល្វែងមួយភាគធំកំពុងតែធ្លាក់ថ្លៃប្រមាណពី20ទៅ40% ដែលតម្លៃនោះធ្វើឱ្យអ្នកលក់ និងអ្នកទិញមានការខកចិត្តខ្លាំងណាស់ ។ ជាមួយនឹងការធ្លាក់តម្លៃនេះ អ្នក ស្រី សុក រស់ អ្នកទិញដីស្តុកទុកដើម្បីយកចំណេញនៅទីក្រុងភ្នំពេញ បាននិយាយទាំងគ្មានព្រលឹងនៅក្នុងខ្លួនថា កន្លងមកគាត់បានយកប្លង់ផ្ទះទៅបញ្ចាំនៅធនាគារ ដើម្បីទិញដីទុកលក់យកចំណេញនៅក្បែរភ្នំបាសិត មានទំហំជិតមួយហិកតា តម្លៃ2ម៉ឺនដុល្លារ កាលនោះគេឱ្យតម្លៃជាង30ម៉ឺនដុល្លារ ហើយប៉ុន្តែគាត់មិនព្រមលក់ទេ ។

អ្នកស្រី សុក រស់ បន្តថា លុះដល់សព្វថ្ងៃនេះគ្មានហាងឆេងបន្តិចសោះ ហើយអ្នកដែលមានដីធំគេសុំទិញឱ្យតម្លៃត្រឹមតែ5ម៉ឺនដុល្លារ

( តនៅទំព័រទី០៩ )

**Washington Wellness Care** មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞របួសដោយគ្រោះថ្នាក់រថយន្ត ☞របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន (215) 380-1350
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ (215) 551-6838

# ប្រវត្តិនៃថ្ងៃ ៧ មករា ឆ្នាំ១៩៧៩

**ដោយ : ពិន សំខុន**

•••ថ្ងៃ ៧ មករា ១៩៧៩ គឺជាថ្ងៃបុណ្យមួយដែលសមាជិកនៃគណបក្សប្រជាជន ប្រារព្វធ្វើជាជ័យជំនះរបស់ខ្លួន ជាមួយនឹងទ័ពយៀកណាមមកលើក្រុមខ្មែរក្រហម ប៉ុល ពត ដឹកនាំដោយសម្តេច សីហនុ នៃប្រទេសកម្ពុជា ។ តើមានអ្វីខ្លះកើតឡើងនៅពេលនោះ ?

ថ្ងៃទី២ ធ្នូ ឆ្នាំ១៩៧៨ ក្រុមខ្មែរ ដែលសម្តេចសីហនុ ឱ្យឈ្មោះថា "ខ្មែរយៀកមិញ" បានរួមប្រជុំនៅ " ស្នួល " ក្រោមការដឹកនាំរបស់ ហេង សំរិន បានធ្វើការប្រកាសវាយប្រឆាំងនឹងក្រុមមួយទៀត ដែលសម្តេចដដែលឱ្យឈ្មោះថា " ខ្មែរក្រហម " ដឹកនាំដោយ ប៉ុល ពត កំពុងត្រួតត្រាលើកម្ពុជា ។ គំនិតបានត្រូវគាំទ្រដោយប្រទេសវៀតណាម និងសូវៀតភ្លាម ដើម្បីឱ្យក្រុមខ្មែរយៀកមិញ អាចវាយប្រហារលើក្រុមខ្មែរក្រហមគាំទ្រដោយចិនប្រជាមានិតបាន ។

ថ្ងៃទី២៥ ធ្នូ ១៩៧៩ : យៀកណាមបានលើកទ័ព១០ម៉ឺននាក់ មកវាយកម្ពុជាតាមខេត្តក្រចេះ ដោយប្រើឈ្មោះសម្ព័ន្ធមិត្តខ្មែរយៀកមិញ ។ ខ្មែរក្រហមគាំទ្រដោយទីប្រឹក្សាយោធា៥០០០នាក់ និងអាវុធយុទ្ធភ័ណ្ឌធន់ធ្ងន់របស់ចិន បានបាក់ទ័ពរត់ទៅព្រំដែនជាប់នឹងថៃឡង់ ។ ខ្មែរក្រហមពេលនោះ ទើបនឹងបាត់បង់ទ័ពស្រួចរបស់ខ្លួន នៅពេលវាយចូលដល់ " ចំពុះទា " នៃប្រទេសយៀកណាម អស់ប្រមាណ៣ម៉ឺននាក់ នៅសល់១ម៉ឺននាក់ ក៏រត់ទៅជ្រកនៅជួរភ្នំដងរែក ម៉ាឡៃ. ប៉ៃលិន ។ ពលរដ្ឋខ្មែរ ពុំបានរត់ទៅតាមការបាត់បង់នោះទេ ហើយបានទទួលទ័ពយៀកណាម និងទ័ព ហេង សំរិន ថាជាអ្នករំដោះខ្លួនពីខ្មែរក្រហម ។

ថ្ងៃទី២ មករា : រំដោះបានក្រចេះ ស្ទឹងត្រែងពីក្រុមខ្មែរក្រហម ។ ក្រុមកុម៉ង់ដូយៀកណាម ដែល មានភារកិច្ចមកចាប់សម្តេច សីហនុ ត្រូវបានក្រុមខ្មែរក្រហមរកឃើញ ។

ថ្ងៃទី៤ មករា ឆ្នាំ១៩៧៩ : ជ្រោយខាងកើតទន្លេមេគង្គទាំងអស់ ត្រូវទ័ពយៀកណាម និង " ខ្មែរយៀកមិញ " យកបាន ។

ថ្ងៃទី៦ មករា ១៩៧៩ : យន្តហោះចិន បានមកដឹកសម្តេច សីហនុ ចេញពីភ្នំពេញ ទៅប៉េកាំង ពេលនោះ សម្តេច សីហនុ ទើបនឹងបានជួបមុខ ប៉ុល ពត ជាលើកដំបូងបង្អស់ នៅវិមានរដ្ឋាភិបាលនៅភ្នំពេញ ។ រីឯនៅ មីមត់ ឯណោះវិញ មេចលនាកុម្មុយនិសយៀកមិញ ទើបនឹងលើកលោក ប៉ែន សុវណ្ណ ជាអគ្គលេខាបក្សនៃចលនារំដោះកម្ពុជារួច ។

ថ្ងៃ ៧ មករា ១៩៧៩ : ប្រទេសកម្ពុជា ទើបនឹងរំដោះចេញពីចលនាកុម្មុយនិសខ្មែរក្រហម ដោយចលនាកុម្មុយនិសយៀកមិញមួយទៀត ។

ថ្ងៃ ៧ មករា ១៩៧៩ គឺជាថ្ងៃបញ្ចប់អំណាចនៃក្រុមខ្មែរក្រហម ដែលបានគ្រប់គ្រងលើកម្ពុជាអស់រយៈពេល១៣៧៥ថ្ងៃ ហើយជារៀងរាល់ថ្ងៃមានកមនុស្សស្លាប់ដោយសារការធ្វើទារុណកម្មចំនួន១១៥០នាក់ ។

**កំណត់និពន្ធ :**

ពលរដ្ឋខ្មែរ បានស្គាល់ " ពន្លឺនៃជីវិត " មួយរយៈ បន្ទាប់ពីដឹងខ្លួនមកវិញ យល់ថាខ្លួននៅក្នុងដង្ក្បេដ៏រឹងមាំនៃកុម្មុយនិសប្រជាមានិតនៅឡើយ ។ ចុងបញ្ចប់អ្នកឈ្នះក៏មិនបាននាំប្រយោជន៍អ្វីដល់ពលរដ្ឋខ្មែរ រីឯអ្នកចាញ់ក៏នៅតែជាពលរដ្ឋខ្មែរដដែល ។ អ្នកដែលទទួលពីការឈ្នះ ឬចាញ់ គឺសមាជិកនៃចលនាបក្សកុម្មុយនិសទាំងអស់រហូតដល់ថ្ងៃនេះ ។

**( ដកស្រង់ពីសៀវភៅគន្លឹះកម្ពុជា )**


## ការិយាល័យមេធាវី លិនហ្សេ ដឺរេ

## LAW OFFICE OF LINDSAY DOERING

**ទទួលការពារផលប្រយោជន៍លោកអ្នកករណីនានាតាមផ្លូវច្បាប់ដូចជា :**

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



**ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**

General practice law office handling matters in :

Corporations and business Transations
Read Estate
Car Accidents
Work Place Injury
Immigration
Criminal Defense
Experienced, professional service and reasonable rate. Interpreter available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com


# ៧ មករា ថ្ងៃយួនជោគជ័យ



**ដោយ : ម៉ម យិន**

ប្រាំពីរ មករា ចិតប្រាំបួន　　ថ្ងៃពួកលក់ខ្លួនបានជោគជ័យ
នាំគ្នាសប្បាយរីករាយក្រៃ　　តាំងចិត្តព្រួតដៃរំឭកគុណ ។
៧ មករា ៧៩　　ថ្ងៃនេះជាក្បួនគ្រោងទុកមុន
ចេញមកពីយួនគេគិតគន់　　ដោយចិត្តលោភលន់មកយូរយា ។
ប្រាំពីរ មករា ចិតប្រាំបួន　　ថ្ងៃខ្មែរត្រៀមខ្លួនរងទុក្ខា
សោកសៅស្រណោះគ្រប់កាយា　　ព្រោះចិត្តប្រាថ្នាយួនលោភលន់ ។
៧ មករា ៧៩　　ថ្ងៃខ្មែរប្រាប់កូនឱ្យល្អិតល្អន់
ថាថ្ងៃនេះពិតជាអាសន្ន　　ព្រោះគេបំភន់ឱ្យខ្មែរភ្លេច ។
ប្រាំពីរ មករា ចិតប្រាំបួន　　ជាថ្ងៃទ័ពយួនគ្រោងការស្រេច
ពិតប្រាកដណាស់តែខ្មែរភ្លេច　　នូវអស់កលល្បិចយួនតែងផ្ចង់ ។
៧ មករា ៧៩　　មានខ្មែររត់ពួនព្រោះខ្លាចបង់
បាត់អស់សិទ្ធិជួយទ្រទ្រង់　　ឱ្យជាតិខ្មែរគង់វង្សយូរយា ។
ប្រាំពីរ មករា ចិតប្រាំបួន　　ខ្មែររត់ភៀសខ្លួនពីរដ្ឋា
ដោយខ្លាចទ័ពយួនចិត្តដូចខ្លា　　នាំទ័ពយោធាចូលពេញស្រុក ។
៧ មករា ៧៩　　ខ្មែរមួយចំនួនហ៊ានចេញមុខ
យល់ច្បាស់ថាយួនចូលវាយលុក　　រឹបអូសភូមិស្រុកទ្រព្យខ្មែរ ។
ប្រាំពីរ មករា ចិតប្រាំបួន　　កងទ័ពសុទ្ធយួនចូលទាំងខ្សែ
ដល់ពីរសែននាក់ខ្លះពូកែ　　វាយយកស្រុកខ្មែរបីអាទិត្យ ។
៧ មករា ៧៩　　ថ្ងៃនោះថ្ងៃយួនធូនល្មមពិត
ជោគជ័យជំនះដូចយួនគិត　　ស្រុកខ្មែរត្រូវស្ថិតក្នុងដៃហើយ ។
ប្រាំពីរ មករា ចិតប្រាំបួន　　ក្រុមខ្មែរពាក់ខ្លួនដើរពីក្រោយ
កងទ័ពយួនមិត្ត ចិត្តពេញដោយ　　ស្រឡាញ់ជាត្រើយសង្គ្រោះខ្មែរ ។
៧ មករា ៧៩　　ខ្មែរត្រូវដឹងខ្លួនហើយគិតគ្នេ
ទ័ពយួនវាយលុកមិនមែនស្នេហ៍　　តាមពិតតែងតែចង់ប្រល័យ ។
ប្រាំពីរ មករា ចិតប្រាំបួន　　ខ្មែរកុំភ្លេចខ្លួន ភ្លេចស្មារតី
ថាជាតិខ្មែរយើងជាចំណី　　ទំល្អប្រពៃសំរាប់គេ ។
៧ មករា ៧៩　　ខ្មែរត្រូវដឹងខ្លួន ហើយត្រូវតែ
រួមសាមគ្គីគ្នារក្សាថែ　　មាតុភូមិជាតិខ្មែរឱ្យគង់វង្ស ។
ប្រាំពីរ មករា ចិតប្រាំបួន　　ខ្មែរពិតធ្លាប់ខ្លួន ហើយលេចលង់
បើខ្មែរយល់ព្រម ហើយបោះបង់　　សាសន៍ជាតិពូជពង្សផងខ្លួនពិត ។
៧ មករា ៧៩　　ជាតិខ្មែរបាត់សូន្យស្លាប់ជីវិត
ហើយជាតិសាសន៍យួនគេមានសិទ្ធិ　　រស់នៅស្ថេរស្ថិតពេញស្រុកខ្មែរហើយ ៕

**កំណាព្យ : ថ្ងៃ ៧ មករា ៧៩ សូមចប់តែប៉ុណ្ណោះ ។**

**សូមអរគុណ !**

(តមកទំព័រទី០១)
# បណ្ឌិតអក្សរសាស្ត្រខ្មែរ...

ខ្មែរម្នាក់ បានលាចាកលោកទៅហើយ កាលពីពាក់កណ្ដាលខែធ្នូ ឆ្នាំ២០០៨ នេះ នៅឯគេហដ្ឋានស្រុកបារាំងរបស់លោក នៅក្រុងម៉ុងមូរ៉ង់ស៊ីជាយក្រុងប៉ារីស ក្នុងជន្មាយុ៨៤វស្សា ។

លោកជាបញ្ញាវន្តខ្មែរដ៏តិចតួច និងដំបូងបង្អស់ ដែលបានសិក្សាស្រាវជ្រាវមិនឈប់ឈរពីប្រវត្តិសាស្ត្រ, អរិយធមិ និងវប្បធមិខ្មែរ ហើយបានធ្វើការផ្សព្វផ្សាយជាពន្លឺជូនដល់ពលរដ្ឋខ្មែរ និងសកលលោក ។

ល្បីល្បាញក្នុងស្រទាប់បញ្ញាវន្ត និងសិស្សានុសិស្ស តែពុំមែនជាទីស្រឡាញ់របស់ស្រទាប់នយោបាយ ឬស្រទាប់គណសង្ឃនោះទេ ។ ជីវិតប្រកបដោយគ្រោះថ្នាក់ជាប្រចាំ ពុំបានឱ្យលោកបោះបង់ការបង្ហាញ់បំភ្លឺលទ្ធផលនៃការស្រាវជ្រាវលើប្រវត្តិវិទ្យា បុរេ-បុរាណ និងបច្ចុប្បន្ននោះទេ។ ការតស៊ូដ៏ស្វិតស្វាញក្នុងជីវិតរបស់លោក ដើម្បីបុព្វហេតុប្រវត្តិសាស្ត្រ- អរិយធមិ និងវប្បធមិខ្មែរ ធ្វើឱ្យយើងខ្ញុំមានមោទនភាពនឹងសរសេរប្រវត្តិសង្ខេបរបស់លោក កេង វ៉ាន់សាក់ ដូចតទៅនេះ :

**ប្រវត្តិសង្ខេបរបស់លោក កេង វ៉ាន់សាក់ :**

កើតនៅថ្ងៃទី១៩ កញ្ញា ឆ្នាំ១៩២៥ នៅកំពុងបឺង សិក្សារហូតបានចប់សញ្ញាប័ត្រមធ្យមសិក្សាផ្នែកទស្សនៈវិជ្ជា នៅឆ្នាំ១៩៤៦ ហើយទៅបន្តការសិក្សានៅប្រទេសបារាំង ។ លោកបានធ្វើជាជំនួយការផ្នែកភាសាខ្មែរ នៅ " វិជ្ជាស្ថានជាតិភាសាបូព៌ាប្រទេស" នៅទីក្រុងប៉ារីស ឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៤៨ ជាជំនួយការភាសាខ្មែរ នៅសាលា (School of Orientals and Africans Studies) នៅទីក្រុងឡុងដុង នៃប្រទេសអង់គ្លេស. - ឆ្នាំ ១៩៥១ ត្រឡប់មកបន្តការងារនៅប្រទេសបារាំង


បណ្ឌិតអក្សរសាស្ត្រាចារ្យ កេង វ៉ាន់សាក់

" វិជ្ជាស្ថានជាតិភាសាបូព៌ា ប្រទេស " រហូតដល់ឆ្នាំ១៩៥២ ។

រៀនផង ធ្វើការជាជំនួយការផង លោក កេង វ៉ាន់សាក់ បានចប់បរិញ្ញាប័ត្រ (Licence es lettres) ខាងអក្សរសាស្ត្រនៅសាលា (Sorbonne) សកលវិទ្យាល័យក្រុងបារីស ឆ្នាំ១៩៥១ ។ នាពេលបំពេញការសិក្សា លោកជាសមាជិកស្ថាបនិកដ៏សំខាន់ម្នាក់ក្នុងរង្វង់ចលនានិស្សិតខ្មែរ ចរន្ត"ម៉ាកសីស" ឆ្វេងនិយម ដែលមានជាអាទិ អនាគតរបស់អ្នកដឹកនាំខ្មែរក្រហមដូចជា : សាឡុតស, អៀង សារី, ជួន មុំ, ខៀវ សំផន, ហ៊ូ យន់, មិន តែប៉ុណ្ណោះ លោកគឺជាសមាជិកដ៏យ៉ាងសកម្មបំផុតរបស់សមាគមនិស្សិតខ្មែរ នៅទីក្រុងប៉ារីស ។

នៅពេលលោកត្រឡប់មកកម្ពុជាភ្លាម លោកបានចូលរួមយ៉ាងសកម្មនឹងចលនាឯករាជ្យជាតិ ដោយបង្កើតបានអង្គុលីលេខខ្មែរ ហើយបញ្ជាទិញម៉ាស៊ីនអង្គុលីលេខចំនួន ២០០គ្រឿង ដែលរដ្ឋ-បាលកម្ពុជា ប្រើរហូតដល់សព្វថ្ងៃនៅឡើយ ។ លោកបាននិយាយថា " បារាំងបានដាក់កំហិតថាម៉ាស៊ីនអង្គុលីលេខខ្មែរ គឺជាមធ្យោបាយសំខាន់បំផុតសំរាប់ទាក់ទងរដ្ឋបាល បើធ្វើហើយប្រើបានទើបប្រគល់ឯករាជ្យមកឱ្យខ្មែរ " ។ ក៏ប៉ុន្តែលោក កេង វ៉ាន់សាក់ បាននិយាយបន្តថា លោកពុំបានទទួលផលពីវិនិយោគលើប្រាក់កាស ចំណោះដឹង និងពេលវេលាសំរាប់បង្កើតអង្គុលីលេខខ្មែរនោះទេ "។ លោក កេង វ៉ាន់សាក់ ត្រូវបានតែងតាំងជាសាស្ត្រាចារ្យវិទ្យាល័យស៊ីសុវត្ថិ នៅពេលដែលត្រឡប់មកពីប្រទេសបារាំងភ្លាម ឆ្នាំ១៩៥២ ដល់ ១៩៥៨ ហើយត្រូវក្រុមប៉ូលិសនៃរដ្ឋបាលសម្ដេចសីហនុ ចាប់ដាក់គុកជាច្រើនសប្ដាហ៍ នាថ្ងៃទី១១ កញ្ញា ឆ្នាំ១៩៥៥ ថ្ងៃបោះឆ្នោតសកលនៅកម្ពុជា ហើយលោក កេង វ៉ាន់សាក ក៏ជាអគ្គលេខាធិការនៃគណបក្សប្រជាធិបតេយ្យដែរ ពេលនោះសង្គមរាស្ត្រនិយមរបស់សម្ដេច សីហនុ បានទទួលនូវជ័យជំនះយកអាសនៈសភាបាន ១០០% ហើយបង្កើតបានជារដ្ឋាភិបាលសង្គមរាស្ត្រនិយមទី១ ដោយមានសម្ដេច សីហនុ ជានាយករដ្ឋមន្ត្រី ។

ឆ្នាំ១៩៥៨ លោក កេង វ៉ាន់សាក់ បានធ្វើជាសាស្ត្រាចារ្យមហាវិទ្យាល័យអក្សរសាស្ត្រ វប្បធមិ និង អរិយធមិនៃសកលវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ និងជាសាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យផង។ នៅឆ្នាំដដែលនោះ លោកបានឡើងជានាយកមហាវិទ្យាអក្សរសាស្ត្រ និងជាចាងហ្វាងនៅវិជ្ជាស្ថានគរុកោសល្យថែមទៀត រហូតដល់ឆ្នាំ១៩៦២ ។

ឆ្នាំ១៩៦៨ លោកត្រូវរដ្ឋាភិបាល " សង្គមរាស្ត្រនិយម " ចាប់ខ្លួនក្នុងក្របខណ្ឌបង្ក្រាបការបះបោរនៅសំឡូត ហើយត្រូវចោទប្រកាន់ថា

(តនៅទំព័រទី១៨)





ប្រធានាធិបតីនៃសហរដ្ឋអាមេរិក
George Washington
John Adams
Thomas Jefferson
James Madison
James Monroe
John Quincy Adams
Andrew Jackson
Martin Van Buren
William Henry Harrison
John Tyler
James Knox Polk
Zachary Taylor
Millard Fillmore
Franklin Pierce
James Buchanan
Abraham Lincoln
Andrew Johnson
Ulysses Simpson Grant
Rutherford Birchard Hayes
James Abram Garfield
Chester Alan Arthur
Stephen Grover Cleveland
Benjamin Harrison
Stephen Grover Cleveland
William McKinley
Theodore Roosevelt
William Howard Taft
Thomas Woodrow Wilson
Warren Gamaliel Harding
John Calvin Coolidge
Herbert Clark Hoover
Franklin Delano Roosevelt
Harry S. Truman
Dwight David Eisenhower
John Fitzgerald Kennedy
Lyndon Baines Johnson
Richard Milhous Nixon
Gerald Rudolph Ford
James Earl Carter, Jr.
Ronald Wilson Reagan
George Herbert Walker Bush
William Jefferson Clinton
George Walker Bush
Barack Obama

# (តមកពីទំព័រទី០១) អ្នកប្រជាធិបតេយ្យ...

សភា កាលពីថ្ងៃទី27 ខែកក្កដា ឆ្នាំ2008 អាណត្តិទី4 មិនទាន់អស់ចិត្តផងនោះ គណបក្សសិទ្ធិមនុស្ស កាលពីពេលថ្មីៗនេះបានធ្វើសន្និសីទកាសែតថា និងធ្វើការចងសម្ព័ន្ធភាព ជាមួយនឹងគណបក្ស សម រង្ស៊ី ដើម្បីដណ្ដើមជ័យជំនះលើគណបក្សប្រជាជនកម្ពុជា (CPP) នៅពេលខាងមុខ ។

ការប្រកាសរបស់គណបក្សសិទ្ធិមនុស្សនោះ គឺយោងទៅតាមសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលស្រឡាញ់លទ្ធិប្រជាធិបតេយ្យ និងបងប្អូនខ្មែររស់នៅក្រៅប្រទេស មានអាមេរិក កាណាដា និងអូស្ត្រាលី ជាដើម ។

ក្នុងសន្និសីទកាសែតនោះ លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សឱ្យដឹងថា គណបក្សលោកគាំទ្រធ្វើសម្ព័ន្ធភាពជាមួយគណបក្ស សម រង្ស៊ី ដែលមានគោលជំហរដូចគ្នា ហើយនៅពេលខាងមុខនេះនឹងពិភាក្សាគ្នា ដើម្បីរកច្រកបញ្ចូលជាគណបក្សតែមួយក្នុងការដណ្ដើមជ័យជំនះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ខែឧសភា ឆ្នាំ 2009 និង2013 ។

លោក កឹម សុខា បន្តថា កន្លងមកយើងបានសហការគ្នាក្នុងក្របខ័ណ្ឌតាំលទ្ធផលការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ គឺពុំបានគិតដល់បញ្ហានេះទេ ។ សម្ព័ន្ធភាពយើងធ្វើឡើងដោយមានការគាំទ្រពីប្រជាពលរដ្ឋខ្មែរ អ្នកស្រឡាញ់ប្រជាធិបតេយ្យទាំងក្នុង និងក្រៅប្រទេស ។

ក្នុងសន្និសីទនោះ មានតែគណបក្សសិទ្ធិមនុស្សមួយទេ ដែលបានចេញសេចក្ដីថ្លែងការណ៍ចងសម្ព័ន្ធភាព ចំណែកឯគណបក្ស សម រង្ស៊ី ពុំឃើញមានអ្វីជាលាយលក្ខណ៍អក្សរទេ ដោយគ្រាន់តែថាទទួលយកសំណើនេះទៅជំរាបជូនលោកប្រធាន សម រង្ស៊ី ជ្រាបប៉ុណ្ណោះ ។


អ្នកសារព័ត៌មានចូលរួមសន្និសីទកាសែតនៅគណបក្សសិទ្ធិមនុស្ស


លោក ជាម យៀប

ចំណែកលោកស្រី មូរ សុខហួរ តំណាងរបស់គណបក្ស សម រង្ស៊ី ក៏បានសម្ដែងនូវការស្វាគមន៍ចំពោះការចងសម្ព័ន្ធភាពរបស់គណបក្សសិទ្ធិមនុស្សនេះដែរ ដោយលោកស្រីបានបង្ហាញពីអ្នកប្រជាធិបតេយ្យត្រូវតែរួបរួមគ្នាទើបឈ្នះ ហើយលោកស្រីនឹងយកបញ្ហានេះទៅពិភាក្សាជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក៏ដូចជាជំរាបជូនលោក សម រង្ស៊ី ផងដែរ ។

ក្នុងសន្និសីទកាសែតនោះដែរ លោកស្រីបានស្ដីបន្ទោសចំពោះរដ្ឋាភិបាលដែលប្រព្រឹត្តអំពើពុករលួយ មិនព្រមអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ហើយគ្មានតម្លាភាព ចំណែកសភាជាតិបែរជាគាំទ្ររដ្ឋាភិបាល ភ្លេចពីតួនាទីរបស់ខ្លួន និងបំបាត់សម្លេងភាគតិចរបស់សភានៃគណបក្សប្រឆាំងក្នុងគណៈកម្មាធិការទាំង 9 ។

លោកស្រី មូរ សុខហួរ ក៏បានបដិសេធមិនទទួលស្គាល់ថ្ងៃ 7 មករា ទេ ពីព្រោះគណបក្សលោកស្រីជាគណបក្សប្រជាធិបតេយ្យ គឺមិនមែនជាគណបក្ស 7 មករា នោះទេ ។

លោក ហង្ស ពុទ្ធា ប្រធានអង្គការនិចហ្វិច ដែលឃ្លាំមើលដំណើរការបោះឆ្នោតនៅកម្ពុជា បានឱ្យដឹងថា គណបក្សទាំងពីរមានមេរៀនក្នុងការបោះឆ្នោតកន្លងមក ។ ដូច្នេះហើយ គណបក្សសិទ្ធិមនុស្ស, គណបក្ស សម រង្ស៊ី មានសិទ្ធិស្វែងរកយុទ្ធសាស្ត្រដើម្បីដណ្ដើមជ័យជំនះនៅពេលខាងមុខ ។

លោក ហង្ស ពុទ្ធា បន្តថា ការរួបរួមគ្នា ឬមិនរួបរួមគ្នា គឺជាចំណុចសំខាន់មួយរបស់គណបក្សដើម្បីឱ្យសម្លេងកាន់តែមានឥទ្ធិពល និងជំនឿទុកចិត្តពីមហាជនកាន់តែច្រើន ។

ចំណែកលោក ជាម យៀប មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា បានថ្លែងថា ចំពោះការចង់រួបរួមគ្នារវាងគណបក្សទាំងពីរ វាជារឿងល្អ ហើយលោកសូមអបអរសាទរ ប៉ុន្តែគណបក្សទាំងពីរមិនមែនធ្វើបាននៅពេលនេះទេ គឺលុះត្រាតែដល់ពេលបោះឆ្នោតអាណត្តិក្រោយមួយទៀត ។

ការបន្ទាន់ឥរិយាបទរបស់គណបក្សសិទ្ធិមនុស្ស ចង់ចងសម្ព័ន្ធភាពជាមួយគណបក្ស សម រង្ស៊ី នេះ ត្រូវបានអ្នកវិភាគមួយចំនួនយល់ថា ក្រុមរបស់លោក កឹម សុខា មួយចំនួនបានរត់ទៅរកអំណាចបុណ្យសក្តិជិតអស់ជាមួយនឹង (CPP) ។ ចំណែកគណបក្សសម រង្ស៊ី ហាក់ដូចជាមិនទាន់ទុកចិត្តគណបក្សសិទ្ធិមនុស្សនៅឡើយ ពីព្រោះគណបក្សប្រឆាំងមួយនេះមានមេរៀនច្រើនណាស់ ៕


AMERICAN LEGION POST 153
PRESENTS



FRANTIC
DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

សូមអញ្ជើញមកលំហែកាយ ពិសារភេសជ្ជៈ
កំសាន្តនៅ "ហ្វ្រង់ទិក"

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

បន្ធូរបរិយាកាសយ៉ាងត្រជាក់ចិត្ត
បន្ទាប់ពីធ្វើការងារហត់នឿយ !

- កន្លែងកំសាន្តធំទូលាយ-ស្ដាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬក៏បុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
- យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
- ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង៩ដល់ម៉ោង៣ព្រឹក **DJ** នឹងបណ្ដែតអារម្មណ៍ លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ





ចង់ជួលសាល ឬចង់បានម្ហូប
ជប់លៀង យើងធ្វើជូនបាន !

HALL RENTAL & CATERING
AVALIABLE REASONABLE PRICE

Randolph C. Smith



Attorney at Law
267-324-6503

សុធា
Office # 1
1819 JFK Blvd.
Philadelphia, Pa 19103

Office # 2
1115 S. 11th St.
Philadelphia, Pa 19147

ការិយាល័យច្បាប់យើងខ្ញុំ មានចំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ ការរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីឧក្រិដ្ឋកម្ម និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក សុធា : (267) 324-6503

We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Imminration.

We will take care of your car and everything else without your pochet expense.

Please contact Sothia at 267-324-6503 for more information.

# Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញឈ្មោះអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

# ឱកាសសំរាប់ជាម្ចាស់ការលើមុខរបរ សំអាតការិយាល័យ

STRATUS BUILDING SOLUTIONS
Rapid Growing Commercial Cleaning Industry



មុខរបរដែលនរណាក៏អាចធ្វើបាន ឱ្យតែមានការព្យាយាម ហើយចង់បានប្រាក់ច្រើន ។ "ស្ត្រាតឹស" គឺជាឱ្យស្សាហកម្មមួយដែលកំពុងរីកចំរើន នៅ ស.រ.អា យើងនឹងផ្តល់ជូននូវ :

- ការហាត់ហ្វឹកហ្វឺនពីមុខរបរនោះ
- យើងជួយឱ្យមុខរបរនោះឱ្យដំណើរការ
- យើងជួយរកទីផ្សារនឹងគ្រប់គ្រងមុខរបរជូន

លោកអ្នកអាចផ្តើមមុខរបរ ដោយមានភ្ញៀវរួចជាស្រេចជាមួយនឹងការងារដែលលោកអ្នកធ្វើបានយ៉ាងងាយស្រួលដោយ :

- យើងផ្តល់ឱកាសសំរាប់ផ្តើមការងារ
- លោកក្លាយជាម្ចាស់នៃការងារ ដោយដាក់ទុនយ៉ាងតិចតួច ដូចជា: ១000 ដុល្លារ
- ធ្វើការតាមពេលដែលលោកអ្នកមាន
- លោកអ្នកត្រូវមានយានជំនិះដែលអាចទុកចិត្តបាន

បើចង់ជ្រាបច្បាស់លើសពីនេះ សូមទាក់ទងទូរស័ព្ទ
ទៅ ចន ខនម៉ាន់ (២១៥) ២៧២_៥៥៣៦
ឬហៅរក សុបិន (២៦៧) ២៥៣_៣៩៤៧

120 GIBRALTAR RD. STE. 109. HORSHAM, PA 19044

មានជួសជុលកែតម្រូវ អាវ ខោ សំពត់
យើងជួសជុលអាវស្បែកផងដែរ
*Professional alternation
*We do LEATHERS!

ទើបបើកថ្មី ហាងសំអាត
សំលៀកបំពាក់ស្ងួត DRY CLEAN

# GRAND OPENING
## MENG´S CLEANERS

454e Wyomimng Ave.Philadelphia Pa 19120

TEL : 215-329-2593

ប្រើម៉ាស៊ីនសំអាតគ្មានជាតិគីមី
ORGANIC MACHINE

ចុះថ្លៃ 20 %
20 % OFF

Start -11/16/08, End-01/16/09
ចុះតម្លៃពីថ្ងៃ ១១/១៦/០៨ ដល់ ០១/១៦/០៩


Khmer Traditional Silk Dress: $3.0


Wool Long Coat: $10


Suites: $ 3.00 a piece.




$1.00 Shirt


Leathers: $28


Jacket: $9.50

នាទី ប្រវត្តិសាស្ត្រ

# ទំព័រហ្វីឡាដែលហ្វីយ៉ា

## ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

**១៩.រដ្ឋាភិបាល នរោត្តម កន្តុល (៦.១០. ១៩៦២.២៥.១៩៦៤)**

. នាយករដ្ឋមន្ត្រី : នរោត្តម កន្តុល

.ទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និង កីឡា : លន់ ណុល

. រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ឡុង បូរ៉េត

. រដ្ឋមន្ត្រីកសិកម្ម : ចៅ សេង

. រដ្ឋមន្ត្រីមហាផ្ទៃទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស : សាក់ ស៊ុតសាខន

. រដ្ឋមន្ត្រីបរទេស : ហួត សម្បត្តិ

. រដ្ឋមន្ត្រីផែនការ : ហ៊ូ យន់

. រដ្ឋមន្ត្រីព័ត៌មាន និងទេសចរណ៍ : ទីម ដុង

. រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ : នរោត្តម ភូរីស្សារ៉ា

. រដ្ឋមន្ត្រីយុត្តិធម៌ : ភី ធៀនឡាយ

. រដ្ឋមន្ត្រីសាធារណសុខាភិបាល : ថៅ ប៉េង ថុង

. រដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៏ : វណ្ណ ម៉ូលីវណ្ណ

. រដ្ឋមន្ត្រីពាណិជ្ជកម្ម : ខៀវ សំផន

. រដ្ឋមន្ត្រីអប់រំជាតិ : ភូ ស៊ីអ៊ុយ

. រដ្ឋលេខាកិច្ចការសង្គម និងការងារ : អ៊ឹង គាត

. រដ្ឋមន្ត្រីឧស្សាហកម្ម : ឈុត ឈឿ

.អនុរដ្ឋលេខាធិការសាធារណការ និងទូរគមនាគមន៍ទទួលបន្ទុក ប្រៃសណីយ៍ និងទូរគមនាគមន៍ និងដឹកជញ្ជូន : អ៊ឹង ក្រពុំផ្កា

.រដ្ឋលេខាធិការមហាផ្ទៃ និងធម្មការទទួលបន្ទុកធម្មការ និងទំនាក់ទំនងជាមួយសភា : ម៉ែន ឈុំ

. អនុរដ្ឋលេខាធិការហិរញ្ញវត្ថុទទួលបន្ទុកថវិកា : ចៅ សៅ

**ថ្ងៃទី២៥តុលា**

អាកាសចរវៀតណាមខាងត្បូងទន្លាក់គ្រាប់បែកលើភូមិខ្មែរ ។

**ឆ្នាំ១៩៦៣**

**ពាក់កណ្តាលខែកុម្ភៈ :**

សិស្ស និងនិស្សិត នៅបាត់ដំបងបានរកឃើញសាកសពសិស្សម្នាក់ ដែលត្រូវទទួលរងគ្រោះដោយការវាយដំដល់ស្លាប់បាននាំគ្នាធ្វើបាតុកម្មប្រឆាំងអំពើឃោឃៅ និងពុករលួយរបស់កងប៉ូលីស ហើយទីស្នាក់ការប៉ូលីសបានត្រូវវាយកម្ទេចពេលនោះមានការទិទាន និងបន្ទោសដល់សង្គមរាស្ត្រនិយមនឹងសម្តេចសីហនុយ៉ាងខ្លាំងរដ្ឋមន្ត្រីត្រូវបានលាលែង ។ សម្តេចសីហនុបានចោទប្រកាន់ថា មានការឃុបឃិតពីសំណាក់អ្នកនយោបាយឆ្វេងនិយម

**តទៅលេខក្រោយ**


# SUNSHINE JEWELRY, INC.

- Fine Jewelry
- Certified Diamonds & Custom Design





## Holiday Specials!

- Up to 50% of on selected diamond jewelry
- SEIKO Watches--25% off on all SEIKO watches
- Special Limited Time Holiday Promotion! 3 Months up to 6 months NO INTEREST.

* Offer is subject to credit approved by GE Money Bank. Promotional applies to all purchase amounts. P romotional begins now through January 31, 2009. See store for details or call.*

**លក់ចុះថ្លៃពិសេសនាឱកាសបុណ្យ**

- អាចបញ្ចុះរហូតដល់ 50% នៅលើពេជ្រដែលជ្រើសរើស
- ចុះថ្លៃ 25% លើគ្រប់នាឡិកា "សៃកូ"
- ចុះថ្លៃពិសេសកំណត់ថ្លៃបុណ្យ ! ពី៣ខែ រហូត ៦ ខែ គ្មានយកការប្រាក់

យើងអាចសុំឱ្យក្រេឌីត នៅ G.E Money Bank បាន សំរាប់គ្រប់ដែលទិញរួមគ្នា ផ្តើមទៅនេះបញ្ចប់នៅថ្ងៃ ៣១ មករា ឆ្នាំ ២០០៩ សូមទូរស័ព្ទរកយើង បើចង់ដឹងបន្ថែម

702 Washington Avenue Phone: (215) 271-2950
Philadelphia, Pa 19147 Fax: (215) 271-2962
Email: colorofsunshine@yahoo.com


## (តមកទំព័រទី០១) ជំនួយសប្បុរសពីខ្មែរនៅ...

ទឹកប្រាក់ចំនួនជាង២២០០០ដុល្លារសហរដ្ឋអាមេរិក នឹងត្រូវឧបត្ថម្ភជូននិស្សិត ដែលមានឈ្មោះតទៅខាងក្រោមនេះ :



FOUNDATION

**List of Scholarship Recipients Year 2008-2009**

http://www.ceefoundation.org/

| Name | Gender | Name | Gender |
|---|---|---|---|
| Nget Rath | M | Chhem Leabheng | M |
| Hok Piseth | M | Soeum Thon | M |
| Ven. Peich Siha | M | Im Chhun Hor | M |
| Ven. Son Hien | M | Son Srey Lak | F |
| Keo Rida | F | Tol Yari | F |
| Heng Phanith | M | Ven. Chan Sophat | M |
| Chay Chanliden | M | Ven. Hin Bunthon | M |
| Chum Phearin | M | Ven. Hoem Sokhom | M |
| Hem Nary | F | Ven. Soll Suvong | M |
| Seng Sokha | M | Chhoeun Navin | F |
| Shin Tula | M | Hang Kim Hourn | M |
| Sok Savry | F | Hay Nita | F |
| Phea Dary | F | Heng Sokea | M |
| Bak Davan | F | Hok Siem | F |
| Bou Monorom | M | Iv Sovan Pidor | F |
| Chea Davith | F | Keo Moniroth | F |
| Chhang Sophy | M | Khoeub Hak | M |
| Chhay Korng Chiv | M | Monh Timsophavin | F |
| Chiv Sophak | M | Nhor Nhen | M |
| Douk Khemera | M | Pao Kimthang | M |
| Eav Saran | F | Phal Kim Seng | M |
| Hak Danet | F | Ry Thida | F |
| Hel Chanthan | M | Sieng Simsorya | M |
| Hin Sophal | M | Sreng Saoroth | M |
| Hoeurn Naichy | F | Srin Sovann | M |
| Huot Phirun | M | Sroy Sreymom | F |
| Ke Kranit | M | Um Chanthan | M |
| Khun Penglay | M | Veng Solina | F |
| Liv Yi | M | Vith Vika | F |
| Ly Samnang | M | Buoy Pisal | M |
| Ly Vuthy | M | Buoy Piseth | M |
| Meas Mardi | F | Chey Keodina | M |
| Nuom Samnith | M | Chhon Channak | F |
| Ouk Mithona | M | Eng Sonita | F |
| Pen Nakry | F | Heng Siv Hong | F |
| Phal Rattana | M | Kaing Menghun | F |
| Soeun Somuny Outdom | M | Khourn Khemry | F |
| Sok Vongreaksa | M | Khy Udom | M |
| Song Kunthea | M | Lim Pheng Un | M |
| Suon Panha | M | Ly Sovongsa | M |
| Tal Tongsreng | M | Moeurng Udam | M |
| Teng Kungmeng | M | Nuth Sohoundany | F |
| Thaung Bophana | F | Pen Chanveasna | M |
| Thorn Ravy | F | Sao Kimsok | M |
| Vaiy Dona | M | Chea Saveth | F |

"មូលនិធិខ្មែរសម្រាប់ការសិក្សា"ជាអង្គការខ្មែរមិនយកកម្រៃដំបូងបង្អស់ រួមប្រជុំដោយសប្បុរសផងស្ម័គ្រចិត្ត ពួតដៃគ្នាទៅជួយសិក្សាធិការរបស់កូនខ្មែរ ជា"អ្នកក្រីក្រតែមានប្រាជ្ញាអាចរៀនបានឆ្ងាយ"ដោយគ្មានរដ្ឋអំណាចណាផ្សេងជួយជាបន្ថែមឡើយ។ លោកវេជ្ជបណ្ឌិត"ខ្ញៅ សំរ៉ង នៅពេលឃោសនារកថវិកាដាក់មូលនិធិ បានធ្លាប់និយាយថា "កម្ពុជាត្រូវការអ្នកចេះដើម្បីរំដោះខ្លួនពីភាពក្រីក្រ និងឱ្យមានសេរីភាពខ្មែរ នៅសហរដ្ឋអាមេរិកនេះ នឹងខិតខំធ្វើឱ្យកូនខ្មែរ ក្លាយទៅជាអ្នកចេះឱ្យបានច្រើន ដើម្បីទៅរំដោះខ្លួន ដោយ



លោកវេជ្ជបណ្ឌិត"ខ្ញៅ សំរ៉ង

(តមកពីទំព័រទី០១)

# ក្លីបព័ត៌មាន

សាធារណជនអាចចូលរួមបានដោយមេត្រីភាព និងដោយគ្មានពិធីការជាផ្លូវការ តែអ្នកសារព័ត៌មាននឹងនៅទីនោះ រង់ចាំស្រង់នូវគំនិត ឬទស្សនៈថ្មីៗដែលនេះជាវេទិកាសេរីរបស់លោកអ្នកអាចប្រើបានដោយមិនបាច់ទើសទ័ល ។

**១-** សុីត ប៉ែន : ខ្ញុំមកនេះជាមួយអតីតយុវជនជាច្រើន ខ្ញុំចូលរួមប្រជុំថ្ងៃនោះ ព្រោះចង់ឃើញខ្មែរចេះរួបរួមគ្នា ចេះស្រឡាញ់គ្នារវាងមហាជនទាំងអស់ មានមនោសញ្ចេតនា ស្គាល់ខុសត្រូវជាមួយគ្នា ។

**២-** ផាន់ណា ផន : ខ្ញុំឃើញមនុស្សមកចូលរួម ដូចជាដោយសប្បាយចិត្ត ខ្ញុំសប្បាយណាស់ដោយបានមកស្គាល់គេឯងច្រើនថ្ងៃនេះ សង្ឃឹមថា ភាពនេះនឹងនៅយូរតទៅទៀត ។

**៣-** រក្សាអាយុ១៦ឆ្នាំ កូនភ្លោះទាំង៣នាក់ :

ខ្ញុំចូលចិត្តធ្វើសក់ឱ្យចំឡែកពីពណ៌ដើមរបស់វាបាត់ទៅហើយ តែសក់នៅតែជារបស់ខ្ញុំ ។

**៤-** រស្មី អាយុ១៦ឆ្នាំ : ខ្ញុំចូលចិត្តធ្វើម្ហូបញ៉ាំក៏ច្រើន ខ្ញុំស្រឡាញ់ភ្លេង និងសិល្បៈច្រើន ។

**៥-** វាស្នា ១៦ឆ្នាំ : ខ្ញុំចូលចិត្តភ្លេងចម្រៀង ខ្ញុំចូលចិត្តម្ហូបខ្មែរ ។

**៦-** ម៉ាក់ អាយុ១៩ឆ្នាំ : ខ្ញុំចូលចិត្តស្ដាប់គេនិយាយគ្នា ស្ដាប់ភ្លេង ហើយចូលចិត្តកីឡា ។

**៧-** លាង ហេង អាយុ១៩ឆ្នាំ សិក្សានៅសាកលវិទ្យាល័យ ជិនស្ដេត : ខ្ញុំអាចជួយធ្វើការផ្សេងៗឱ្យសមាគមន៏ខ្មែរ នៅអាមេរិកាំងក៏បាន នៅស្រុកខ្មែរក៏បាន នេះជាគំរោងរបស់ខ្ញុំនៅពេលដែលនាងខ្ញុំរៀនចប់ គឺជាការសងគុណដល់មាតុប្រទេសរបស់ខ្ញុំវិញ ខ្ញុំប្រាថ្នាជួយសហគមន៏ខ្មែរ នៅហ្វីឡាដែលហ្វីយ៉ា នេះផងដែរ ។

**៨-** នីតា សាកលវិទ្យាល័យ ជេនស្ដេត :

នាងខ្ញុំចូលចិត្តស្ដាប់ចំរៀង គូរគំនូរ ចង់រៀនខាងគូរគំនូរផ្ទះ...។

**៩-** ភឿ គួន ១៩ : រៀនសង្គមវិជ្ជា នៅឯសាកលវិទ្យាល័យ ជេន ស្ដេត ខ្ញុំចង់ឃើញខ្មែរចេះជួយគ្នាក្នុងសហគមន៏ដូចពួកកូរ៉េ គេប្រើប្រាស់លុយជួយគ្នាក្នុងសហគមន៏គេ ។

**១០-** សារ៉ាត : ខ្ញុំជាម្ចាស់រង្គសាលមួយ បើកបីឆ្នាំហើយ កំពុងមានដំណើរការល្អ ការស្រម៉ៃរបស់ខ្ញុំចង់ឃើញសហគមន៏យើងនៅជាមួយគ្នាថ្ងៃនេះ យើងជួបជុំគ្នាជួយគ្នាឱ្យងើបរួចរហូតដល់បានដូចសហគមន៏ចិន ឬយួន ។

**១១-** អ្នកស្រីខៃរី : ខ្ញុំចង់មកគាំទ្រចលនាកាសែត នៅហ្វីឡាដែលយ៉ា ទើបខ្ញុំមកថ្ងៃនេះ។

**១២-** ប៊ុល ខៃរី : បើចង់ដឹងពីរង្គសាលខ្ញុំធ្វើអ្វីខ្លះ សូមអានកាសែត ។

**១៣-** វណ្ណា : ខ្ញុំចង់ឃើញខ្មែរ នៅហ្វីឡាដែលយ៉ារីកចំរើន ពេលខ្លះខ្ញុំចង់ចេញទៅញ៉ាំម្ហូបខ្មែរ នៅខាងក្រៅតែដូចជាអត់មានទេ ។

**១៤-** ឡេា បុផ្ផា មកពីកាលីហ្វ័រនីញ៉ា : ខ្ញុំចង់ឃើញ ហ្វីឡា មានខ្មែរជាច្រើន ហើយបង

(តទៅទំព័រទី១៩)


សុីត ប៉ែន


ផាន់ណា ផន


រក្សា កូនភ្លោះទាំង៣នាក់ រស្មី វាស្នា


ម៉ាក់


លាង ហេង

FreeLife
The Himalayan Goji Company®




# the World's Most Powerful Anti-Aging Food

## ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក គឺទឹកផ្លែឈើ "គោជី " នៃព្រៃហេមពាន្ត

HIMALYAN GOJI
Juice



ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាសុីបានត្រូវរកឃើញ នារជ្ជកាលស្ដេចតាំងឆ្នាំ ៨00 គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្ដូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្ដិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

បើចង់បាន Goji មកពិសារសូំជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

SHARE THE SECRET

TIME Magazine wrote :

*" this year's breakout (Superfruit ) was the Himalyan Goji Berry, said to be a source of energy and longevity ".* To order, please visit the website at : **www.forever.freelife.com**

**Or please call (267) 253-3947 to order**















# ចង់ចេញពីភាពទ្រុឌទ្រោម? RELIV អាចប្តូររូបរាងកាយឲ្យមាំទាំបាន



Dr. Earleen Ong, Fellow of Geriatric Medicine, Certified Family Physician
Dr. John Harold Ong, Orthomolecular Medicine, Associate of Geriatric Medicine

**Reliv: Nutrition for the 21st Century**

Today's modern processing techniques rob essential nutrients from much of our food. Reliv restores the balance by delivering a unique blend of the vitamins, antioxidants, minerals, proteins, amino acids and phytonutrients the body needs to restore energy, fight off infections and feel great — every day.




WWW.RELIV.COM

- ពិសារ Reliv រាល់ថ្ងៃ គឺនាំឱ្យមានកម្លាំងកាយ រូបរាងមាំមួន សម្ផស្សស្រស់បស់ឡើងបាន
- Reliv អាចទប់ស្កាត់នូវជំងឺមួយចំនួនធំ ដែលកើតមក ពីការពិសារចំណីអាហារខ្វះជីវជាតិ ធ្វើឱ្យសរីរាង្គតាំងដំណើរ
- ពិសារ Reliv លោក-អ្នកនឹងដឹងពីប្រសិទ្ធភាព ចាប់តាំងពីថ្ងៃដំបូង ដែលលោក-អ្នកប្រើ Reliv នេះភ្លាម ។

សូមទូរស័ព្ទជាវនៅលេខ : (636) 537 9715
. ដោយផ្តល់លេខសំគាល់ : RNC .7070 438001
បញ្ជាទិញ 1. RELIV CLAASIC មួយកំប៉ុង
2. Reliv INNERGINE មួយកំប៉ុង ដែលជាចំណីជីវជាតិ
លាយ RELIV 1 និង RELIV 2 ម្នាងមួយស្លាបព្រាក្នុងទឹកផ្លែឈើហើយពិសារម្តង ឬពីរដងក្នុងមួយថ្ងៃ ទៅតាមភាពទ្រុឌទ្រោមនៃរូបរាងកាយ
" ភាពរឹងមាំកើតឡើងស្ទើរជឿមិនបាន "

ម្យ៉ាងវិញទៀត : នៅពេលឃើញប្រសិទ្ធភាពនៃ Reliv លោកអ្នកនឹងមានជំនឿថា អាចចែកចាយឱ្យមនុស្សច្រើនទៀតបាន
សូមទាក់ទងមកយើងខ្ញុំ ដើម្បីចុះឈ្មោះជា RELIV DISTRIBUTOR បន្តទៅទៀត លោកអ្នកអាចនឹងចំណេញប្រាក់ច្រើន
ដោយសារតែបានជួយអ្នកដទៃឱ្យមានសុខភាពល្អដូចលោកអ្នកបាន
ទូរស័ព្ទនៅ Philadelphia : **(267) 254 8758** នៅ **VIRGINIA**
**703 415- 6257**

(តមកពីទំព័រទី ១១)

# បណ្ឌិតអក្សរសាស្ត្រខ្មែរ...

"ជាមេក្លោងនៃទ័ពព្រៃកុម្មុយនិស្ត ។ លោកត្រូវបានចេញពីគុកវិញ ឆ្នាំ១៩៦៩ លោកធ្វើការនៅសកលវិទ្យាល័យវិចិត្រសិល្បៈ ផ្នែកខាងសិលាចារឹក រហូតដល់ឆ្នាំ១៩៧០ ហើយបានផ្តល់ការគាំទ្រដល់ចលនាផ្តួលរំលំរបបសម្តេច សីហនុ ១៨ មិនា ១៩៧០ ។ លោកបានអាហារូបករណ៍ទៅរៀន យកថ្នាក់បណ្ឌិតនៅប្រទេសបារាំង នៅថ្ងៃទី២៥ មេសា ឆ្នាំ១៩៧០ ហើយបានទទួលសញ្ញាប័ត្របណ្ឌិត ផ្នែកអក្សរសាស្ត្រពីមហាវិទ្យាល័យ (Sorbanne) ឆ្នាំ១៩៧១ ។ លោកត្រឡប់មក កាន់វិជ្ជាស្ថានខ្មែរ-មន នៅភ្នំពេញវិញ ខែកក្កដា ឆ្នាំ១៩៧១ ហើយត្រឡប់ទៅទទួលឋានៈជាតំណាងសាធារណរដ្ឋខ្មែរ ប្រចាំអង្គការយូណេស្កូ នៅប្រទេសបារាំង ខែកក្កដា ឆ្នាំ១៩៧១ បន្ទាប់មកជាភារធារីសាធារណរដ្ឋ ពីខែវិច្ឆិកា ឆ្នាំ១៩៧៤ ដល់ខែមេសា ឆ្នាំ១៩៧៥ ។

លោក កេង វ៉ាន់សាក ពុំបានចូលរួមក្នុងចលនាកុម្មុយនិសខ្មែរក្រហមក្នុងការដណ្តើមជ័យជំនះលើសាធារណរដ្ឋខ្មែរទេ ហើយបានសុំសិទ្ធិច្រកកោននៅក្នុងប្រទេសបារាំង តាំងពីឆ្នាំ ១៩៧១ មកឯណោះ ។

ពីឆ្នាំ១៩៧១ នោះមក លោកបានធ្វើការស្រាវជ្រាវជាច្រើន យ៉ាងស្មៀមស្ងាត់ទៅលើវប្បធម៌ និងអរិយធម៌ខ្មែរ នៅប្រទេសបារាំង ដែលសម្បូរ ដោយឯកសារចម្លងត្រឹមត្រូវ ហើយលោក គឺជាបញ្ញវន្តខ្មែរតែម្នាក់គត់ ដែលបានកំណត់យកសកម្មភាពនយោបាយដាក់ក្នុងក្របខណ្ឌនៃការពិចារណាទៅលើអរិយធម៌ និងទៅលើវប្បធម៌ខ្មែរ ។

លោក កេង វ៉ាន់សាក់ បានបន្សល់ទុកនូវស្នាដៃនិពន្ធកំណាព្យជាច្រើនដូចជា : បេះដូងក្រមុំ ឆ្នាំ១៩៤៥, គុកកាមកិលេសឆ្នាំ១៩៥៥, ចាប៉ីដងវែង ឆ្នាំ១៩៧៣ ។ល។ មានសរសេរជារឿងល្ខោន និយាយដូចជា : អន្ទិតគោលោត ឆ្នាំ ១៩៤៥ ។ល។ មានសរសេរជាអត្ថបទសាកល្បងស្រាវជ្រាវ "គោលការណ៍សម្រាប់បង្កើតពាក្យថ្មី" មហាវិទ្យាល័យអក្សរសាស្ត្រ នៅឆ្នាំ១៩៦៤ - " សម្លេងនៃអក្សរខ្មែរ " គឺការសិក្សាប្រៀបធៀបពាក្យខ្មែរទៅនឹងសំស្ក្រឹត ឬបាលី ឆ្នាំ១៩៦៦, -"មានការសរសេរជាភាសាបារាំង អំពី " ទិដ្ឋភាពខ្លះៗនៃវប្បធម៌ខ្មែរ ឆ្នាំ១៩៦៥ " - "រាមកេរ្តិ៍ ឬរាម៉ាយ៉ាណាខ្មែរ" ឆ្នាំ ១៩៦៩ ។ ឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០០៨ លោក កេង វ៉ាន់សាក់ បានផ្តល់បទសម្ភាសន៍ជាប្រចាំ ស្តីអំពីប្រវត្តិសាស្ត្របូរាណកាល និងបច្ចុប្បន្នកាល វប្បធម៌ និងបទពិសោធន៍ដ៏ច្រើនឥតគណនា ជាចំណេះមិនអាចកាត់ថ្លៃបានជូនដល់មនុស្សជាតិ នៅវិទ្យុអាស៊ីសេរីផ្សាយពីសហរដ្ឋអាមេរិក ។

លោក បណ្ឌិត កេង វ៉ាន់សាក់ បានលាចាកលោកនេះទៅនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ដោយពុំមានបន្សល់ទុកនូវបុត្រា ឬបុត្រីបន្តពូជនោះទេ ។ ភរិយាដ៏កំសត់កំររបស់លោក បានទទួលមរណភាពកាលពី ២ឆ្នាំមុន ហើយនៅដើមឆ្នាំ២០០៨ នេះ លោកបានរៀបការជាមួយស្ត្រីខ្មែរម្នាក់ឈ្មោះ សុវណ្ណ ដើម្បីឱ្យជួយថែជរាភាពរបស់លោក ជាថ្នូរនឹងកេរ្តិ៍អាករទាំងអម្បាមាន ដែល



បណ្ឌិតអក្សរសាស្ត្រាចារ្យ កេង វ៉ាន់សាក់

លោកមានជាសម្បត្តិទុកឱ្យដល់ពេលលោកចូលមរណភាពទៅ ។

**កំណត់និពន្ធ :**

បណ្ឌិត កេង វ៉ាន់សាក ជាមនុស្សធ្វើការមិនឈប់ឈរ សរសេរអក្សរដូចបោះពុម្ព ហើយមានសេចក្តីរីករាយណាស់ និងផ្សព្វផ្សាយពីចំណេះដឹងរបស់លោក ដោយមិននឿយហត់ បើមាននរណាម្នាក់ចង់ដឹងចង់យល់ ។ តែជំនាញរបស់លោក ត្រូវបានលោកធ្លាប់ពន្យល់ថា "មិនជាទីចំណូលចិត្តរបស់សម្តេចសង្ឃ ដែលពូកែខាងបាលីសំស្ក្រឹត រីឯលោកវិញ ដែលពូកែខាងមន-ខ្មែរ ដែលមានអាយុចាស់ជាងគេ សំស្ក្រឹត ឬបាលី-ខ្មែរ" លោកបន្តថា " សម្តេច សីហនុ នៅពេលដែលចាប់ដាក់គុក គឺបំពេញបំណងសម្តេចសង្ឃផង និងខ្លួនព្រះអង្គផង " ។

ខ្ញុំបានទៅជួបសម្ភាសន៍ជាមួយលោកបណ្ឌិត កេង វ៉ាន់សាក់ នៅគេហដ្ឋានបារាំងរបស់គាត់ជាច្រើនដង នាអំឡុងឆ្នាំ២០០០ ខ្ញុំបានឃើញសម្បត្តិដ៏សំខាន់បំផុត ជាទីស្រឡាញ់របស់លោកបណ្ឌិត គឺសៀវភៅ ឬឯកសារសម្លេង ឬរូបភាព ឬភាព-យន្ត នៅគ្រប់ទីកន្លែង កៀនកោះ ហើយភាគច្រើនជារបស់ដែលសាធារណជន ឬសិស្សានុសិស្សពុំដែលបានរៀនសូត្រពីប្រវត្តិរបស់ខ្លួន ពីព្រោះជារបស់ហាមឃាតដោយព្រះបរមរាជវាំង ឬដោយវត្តអារាម ។

លោកបានចែកកេរ្តិ៍អាករដល់កូនចិញ្ចឹមស្រីប្រុសរបស់លោកម្តងហើយ នាមុនឱកាសប្រពន្ធបារាំងរបស់គាត់បានស្លាប់ គឺផ្ទះ និងដីធ្លី នៅតំបន់ "ន័រម៉ង់ឌី " ។ នៅចុងបញ្ចប់នៅជីវិតរបស់លោក គឺឱ្យផ្ទះ និងដីធ្លីទៅកូនចិញ្ចឹមថ្មីម្នាក់ទៀត ក្នុងរូបភាពជាភរិយាក្រោយ ដើម្បីងាយស្រួលការផ្ទេរសម្បត្តិរបស់លោកទៅឱ្យនាង ៕

**( ដកស្រង់ចេញពីសៀវភៅគន្លឹះនៃកម្ពុជា និងបទសម្ភាសន៍ខ្ញុំផ្ទាល់ (ពិន សំខុន) ជាមួយលោកបណ្ឌិត កេង វ៉ាន់សាក់ ) ៕**

# ស្ត្រីខ្មែរ ជាប់ទវជន CNN

•••អ្នកស្រី នួន ភិមាន ដែលកំពុងស្ថិតនៅក្នុងប្រទេសកាណាដា បានផ្តល់បទសម្ភាសន៍តាមទូរស័ព្ទជាមួយតំណាងទស្សនាវដ្តីខ្មែរអប្សរា ដោយអ្នកស្រីបានប្រាប់ថា អ្នកស្រីជាកូនអ្នកខេត្តកំពង់ចាម ហើយបានចាប់ផ្តើមធ្វើសកម្មភាពមនុស្សធម៌ជួយក្មេងៗនៅតំបន់ចោលសំរាមស្ទឹងមានជ័យ ដោយសារតែបានជួបប្រទះនឹងភាពអណោចអធ័មនៃក្មេងៗ កំព្រាមួយគ្រួសារ ។ ហើយផ្តើមពីនេះ អ្នកស្រីក៏បានបង្កើតមជ្ឈមណ្ឌលសង្គ្រោះដល់ទៅ3សំរាប់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្នាក់នៅដោយអ្នកស្រីទទួលយកក្មេងៗប្រមាណជាង 1.000នាក់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ។ សព្វថ្ងៃគឺមានក្មេងស្នាក់នៅទទួលការឧបត្ថម្ភគ្រប់យ៉ាងក្នុងបន្ទុកប្រមាណជាង600នាក់ ។

មជ្ឈមណ្ឌលនីមួយៗ គឺមានការបង្រៀនផ្នែកចំណេះទូទៅដូចជាសាលារដ្ឋ និងមានការទទួលស្គាល់ពីក្រសួងអប់រំផង និងរៀនភាសាអង់គ្លេស ។ ក្រៅពីនេះ មានការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកកាត់សក់ ធ្វើសក់ កាត់ដេរ កុំព្យូទ័រ... ។ល ។

អាស្រ័យដោយអ្នកស្រីមានគុណសម្បត្តិមួយនេះ និងដោយការខ្នះខ្នែងយកកេរ្តិ៍ឈ្មោះតាមរយៈម្ចាស់ជំនួយ អ្នកស្រីត្រូវបានគេបញ្ចូលឈ្មោះជា បេក្ខជន វីរជន ប្រចាំឆ្នាំ2008 របស់ទូរទស្សន៍ CNN ។ ប៉ុន្តែអ្វីដែលគួរឱ្យស្ងើចបំផុតនោះ គឺថានៅក្នុងចំណោមបេក្ខជន 3.700នាក់ មកពីគ្រប់ទិសនៃពិភពលោក អ្នកស្រីបានជាប់



ក្នុងជំរើស10នាក់នៃការជម្រុះលើកចុងក្រោយ ដែលនេះ គឺជាមោទនភាពមួយសំរាប់ជនកម្ពុជាពិសេសគឺស្ត្រីកម្ពុជាតែម្តង ។ ក្នុងចំណោម10នាក់នេះ CNN បើកឱ្យមានការបោះឆ្នោតដោយសេរី តាំងពីឥឡូវនេះទៅតាមរយៈវេបសាយ CNN.com/hero ។ ការវិនិច្ឆ័យចុងក្រោយដើម្បីនឹងផ្តល់រង្វាន់10ម៉ឺនដុល្លារអាមេរិកនោះ ទូរទស្សន៍ CNN គ្រោងធ្វើនៅក្នុងសាលមហោស្រពហូលីវូដ នាថ្ងៃទី22 ខែ វិច្ឆិកា ឆ្នាំ2008 ហើយគេនឹងផ្សព្វផ្សាយជាសាធារណៈពេញពិភពលោកនៅថ្ងៃទី27 ខែវិច្ឆិកា ឆ្នាំ2008 ។ ការជាប់ជាជំរើស10នាក់ដំបូងនេះ បេក្ខភាពម្នាក់ៗ ទទួលបាន25.000 ដុល្លាររួចហើយ ហើយ10ម៉ឺនដុល្លារ គឺជាប្រាក់រង្វាន់សំរាប់បន្ថែមដល់បេក្ខភាព ដែលជាប់ជ័យ-



អ្នកស្រី នួន ភិមាន



អ្នកស្រី នួន ភិមាន និងកុមារ នៅសំរាមស្ទឹងមានជ័យ

លាភីនៅវត្តផ្កាចព្រាត្រ ។

សួរថា តើអ្នកណាដែលជំរុញ ឬបានដាក់ឈ្មោះអ្នកស្រី ទៅប្រកួតប្រជែងយករង្វាន់ដ៏អស្ចារ្យមួយនេះ អ្នកស្រី នួន ភិមាន ប្រាប់ថា ការពិតទៅអ្នកស្រីមិនដឹងខ្លួនទេ តែកាលពីខែមេសាកន្លងទៅ ស្រាប់តែខាង CNN គេទូរស័ព្ទមកប្រាប់ និងសាកសួរពីសកម្មភាពអ្នកស្រី ។ អ្នកស្រីនិយាយថា រង្វាន់ជាវីរជន CNN នេះទើបតែបង្កើតបាន2ឆ្នាំ ហើយលើកនេះ គឺជាឆ្នាំទី2 ។ ដោយឡែកសំរាប់អ្នកស្រី គឺលោកគ្រូជាតិកាណាដា នៅសាលាដែលអ្នកស្រីកំពុងរៀន គាត់បានឧទ្ទេសនាមឱ្យទៅ CNN ដោយមិនទាំងប្រាប់ឱ្យអ្នកស្រីបាន ដឹងជាមុនផងទេ ។ ការជ្រើសរើសនេះ សំរាប់បេក្ខភាពនីមួយៗ គឺមិនមែនសាមីខ្លួនគិតប្រាថ្នា និងដាក់ពាក្យខ្លួនឯងទេ ប៉ុន្តែ គឺចាំបាច់ត្រូវមានអ្នកឧទ្ទេសនាម និងស្នើសុំដោយផ្អែកលើសកម្មភាពខ្លាំងក្លារបស់បុគ្គលម្នាក់នោះថាមានចរិត សីលធម៌ បានបំរើសង្គមអ្វីខ្លះ មានប្រវត្តិតស៊ូយ៉ាងម៉េច ទទួលបានជោគជ័យអ្វីខ្លះ ។ អ្នកដែលត្រូវបានគេឧទ្ទេសនាមទាំងអស់នឹងត្រូវគេជ្រើសជំរុះជាបីលើក លើកទី1មិនដឹងជាយកប៉ុន្មានប្រាកដទេ អ្នកស្រីមិនចាំ ។ តែលើកទី2 គឺគេជ្រើសយក32នាក់ ហើយលើកទី3 ជ្រើសយក10នាក់សំរាប់ដាក់ឱ្យមហាជនទូទាំងពិភពលោកបោះឆ្នោត ដើម្បីសំរេចយកជាវីរជនឯកចុងក្រោយ ដែលត្រូវបន្ថែមប្រាក់រង្វាន់10ម៉ឺនដុល្លារ នៅក្នុងថ្ងៃប្រគល់រង្វាន់បញ្ចប់ពិធីប្រចាំឆ្នាំនីមួយៗ ។

អ្នកស្រីបានចាប់អារម្មណ៍អំពីសកម្មភាពកន្លងមកថា គឺភាពសង្វេគ អាណិតអាសូរនឹកទៅដល់ក្មេងៗដែលអ្នក ស្រីបានឃើញពួកគេរស់នៅលើគំនរសំរាម ដែលជួបនូវការលំបាកវេទនាឈឺស្កាត់អត់អាហារ គ្មានការអប់រំរៀនសូត្រក្លាយជាជនបាតសង្គមប្រព្រឹត្តនូវរឿងអសីលធម៌ ។ កត្តាទាំងអស់នេះ បានជំរុញឱ្យអ្នកស្រីសំរេចបើកមជ្ឈមណ្ឌលទទួលយកពួកគេមកស្នាក់នៅអប់រំផ្តល់អាហារ សម្លៀកបំពាក់ ការព្យាបាល ឱ្យទៅរៀនសូត្រ ហើយទីបំផុតក្មេងៗ មួយចំនួនក៏បានក្លាយជាពលរដ្ឋល្អក្នុងសង្គមកម្ពុជា ដែលរដ្ឋយើងពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ នឹងជួយសង្គ្រោះបាន 100% ។

(តទៅទំព័រទី២៣)

# វិយោគកថាជូនលោកបណ្ឌិត កេង វ៉ាន់សាក់

ដោយ : ម៉ម យិន

លោកបណ្ឌិតសាស្ត្រាចារ្យកេង វ៉ាន់សាក់បានថែងតុកមកថា
លោកជាអ្នកប្រាជ្ញជាតិខេមរា ល្បីល្បាញអស្ចារ្យគួរស្រឡាញ់ ។
លោកបានសិក្សាអក្សរសាស្ត្រចេះ ចាំយល់ច្បាស់ដោយពេញលេញ
ទើបត្រឡប់មកស្រុកខ្មែរវិញ ដើម្បីបំពេញសងគុណជាតិ ។
វីរភាពដ៏ខ្ពស់លោកបណ្ឌិត វិសេសវិសិដ្ឋពេញដល់ខ្នាត
បង្រៀនកូនខ្មែរឱ្យសង្វាត តាមបែបបទបាទជាកូនខ្មែរ ។
នៅពេលសង្គមខ្មែររងទុក្ខ បារាំងបានផ្ទុកអំណាចរិទ្ធិ
ត្រួតត្រាលើខ្មែរតាមតែចិត្ត តែលោកបណ្ឌិតពិតពុះពោ ។
ខិតខំបង្រៀនប្រៀនប្រដៅ ដល់អស់កូនចៅជាតិខេមរា
ឱ្យចេះឱ្យដឹងនូវវិជ្ជា ទើបខ្មែរគ្រប់គ្នាមានកេរ្តិ៍ឈ្មោះ ។
កិត្តិយសឧត្តមលោកបណ្ឌិត ថ្លៃថ្លាពិសិដ្ឋនៅពេលនោះ
នាំខ្មែរសោកសៅសែនស្រណោះ មិនគួរឡើយសោះលោកអភ័ព្វ ។
តម្លៃកេរ្តិ៍ឈ្មោះវីរភាព មិនស្ថិតដរាបនៅនិតជាប់
ត្រូវខ្មែរក្រហមវាចោមស្ទប់ រួចរកសម្លាប់លោកចោលទៀត ។
តែវាសនាល្អលោកបានរត់ ចាកចេញរួចផុតហើយឈ្លាសឆ្លៀត
ទៅនៅបារាំងគ្មានក្រុមញាតិ តែចិត្តមិនឃ្លាតពីជាតិខ្មែរ ។
គួរសោកស្តាយណាស់ខ្មែរអ្នកប្រាជ្ញ ត្រូវជនកោងកាចចាប់ហួរហែ
យកទៅពិឃាតស្ទើរសឹងតែ ស្លាប់អស់ប្រាជ្ញខ្មែរស្នេហ៍ជាតិពិត ។
បណ្ឌិតវ៉ាន់សាក់ត្រូវរងទុក្ខ លំបាកគ្រប់មុខគ្រាំគ្រាចិត្ត
ដោយខ្មែរក្រហមគ្មានអាណិត ទៅដល់ជីវិតអ្នកប្រាជ្ញខ្មែរ ។
ដបប្រាំបី ធ្នូ សូន្យប្រាំបី លោកលាលោកីយដោយសារតែ
រោគទឹកចូលសួតពេទ្យខំថែ ជួយមិនរួចទេ លោកត្រូវស្លាប់ ។
ជីវិតបណ្ឌិតបាត់បង់ទៅ តែបន្សល់នៅទុក្ខបៀមជាប់
លើកាយកូនខ្មែរដែលបានធ្លាប់ ស្រឡាញ់គោរពដល់បណ្ឌិត ។
ប៉ុន្តែពួកខ្មែរក្រហមឆ្កួត ជាក្រុមចិត្តខ្មៅតែងប្រព្រឹត្ត
សម្លាប់ជាតិខ្មែរស្នេហ៍ជាតិពិត ក្រុមនេះស្នេហ៍ស្និទ្ធតែក្រុមចោរ ។
វាគ្មានដែលគិតដល់ជាតិខ្មែរ ប្រាជ្ញព្រឹទ្ធពូកែមានពេញពោរ
វាមិនដែលស្គាល់ហើយរាប់រ ជាប្រាជ្ញបវរក្រុមវាឡើយ ។
ដូច្នេះ ពេលនេះលោកបណ្ឌិត កេង វ៉ាន់សាក់ ពិតលោកឃើញហើយ
មានតែជាតិខ្មែរធ្លាប់ផ្តល់ឱ្យ ស្រឡាញ់កៀកកើយលោកវ៉ាន់សាក់ ។
យើងខ្ញុំទាំងអស់សោកស្តាយណាស់ នៅពេលដឹងច្បាស់លោកមរណៈ
នៅប្រទេសគេជាពុំនាក់ សល់តែធាតុដាក់នៅស្រុកខ្មែរ ។
ជាតិខ្មែរស្នេហ៍ជាតិសូមគោរព ហត្ថាប្រសប់សូមបន់បែ
សូមវិញ្ញាណក្ខន្ធបានជួបតែ ក្តីសុខគ្មានប្រែពិតជាសុខ ។
ម្យ៉ាងទៀតយើងខ្ញុំទាំងអស់គ្នា ចងចាំវាចាលោកថែងទុក
បង្រៀនវិជ្ជាសព្វគ្រប់មុខ សំរាប់នាំស្រុកជាតិសុខសាន្ត ។
តែស្អប់ខ្ពើមណាស់ដល់ខ្មែរក្បត់ វាបានកំណត់ដោយបំពាន
ព្រមលក់ចិត្តហើយលក់ទាំងកាយ ធ្វើចិត្តសាមានសម្លាប់ប្រាជ្ញ ។
សូមជាតិខេមរាស្នេហាជាតិ ក្រោកឡើងព្រោងព្រៀតមិនត្រូវខ្លាច
រួមសាមគ្គីប្រើអំណាច សិទ្ធិអ្នកប្រាជ្ញធ្លាប់ប្រដៅ ។
មិនត្រូវនៅស្ងៀមនៅព្រងើយ ក្រោកឡើងខ្មែរអើយនាំគ្នាទៅ
ជួយសង្គ្រោះជាតិបានគង់នៅ តាមប្រាជ្ញតម្រូវបង្រៀនមក ។
ខ្ញុំសូមជូនពរខ្មែរស្នេហាជាតិ សុខសាន្តកុំឃ្លាតមានជ័យជោគ
អាយុយឺនយូរគ្មានទុក្ខសោក ដូចប្រាជ្ញដែលលោកតែងបង្រៀន ។
សូមឱ្យប្រទេសជាតិខេមរា គង់វង្សគ្រប់គ្រាដូចប្រាជ្ញប្រៀន
ប្រដៅកូនខ្មែរញាតិព្រៀងលាន បានសុខរស់រានជានិរន្តរ៍អើយ ៕

សូមដួងព្រលឹងវិញ្ញាណលោកបណ្ឌិតសាស្ត្រាចារ្យ កេង វ៉ាន់សាក់ បាន សោយសុខនៅក្នុងសុគតិភពកុំបីឃ្លាងឃ្លាតឡើយ ។

សូមអរគុណ !

# ក្លឹបព័ត៌មាន

(តមកពីទំព័រទី១៦)




ប្អូនយើងចូលចិត្តគាំទ្រវប្បធម៌ជាតិ ធ្វើឱ្យភ្លេងចម្រៀង និងវប្បធម៌នៅតែជាខ្មែរដដែល ។ នាងខ្ញុំធ្វើជាអ្នកគ្រូបង្រៀនផង ជាអ្នកចម្រៀងផង ព្រោះតាំងតែពីនាងខ្ញុំមកដល់សហរដ្ឋអាមេរិក តាំងពីតូចមកចូលចិត្តច្រៀងចំរៀងខ្មែរ ទោះទៅធ្វើជាគ្រូក្តី ក៏ឆ្លៀតប្រើចំណេះនេះ មកច្រៀងកំសាន្តដែរ ។ ឥឡូវនេះ ខ្ញុំកំពុងប្រមូលសៀវភៅឱ្យកូនខ្មែររៀន ខ្ញុំសូមអំពាវនាវដល់បងប្អូនដែលនៅសល់សៀវភៅរៀនសូត្រ សូមកុំចោល ទុកឱ្យនាងខ្ញុំប្រមូលទៅឱ្យកូនខ្មែរយើងដែលត្រូវការ ។

**១៥-** ទូច : ខ្ញុំដឹកនាំភ្លេង " មនោរម្យ " ខ្ញុំមិនហ៊ានថា ក្រុមខ្ញុំពូកែប៉ុណ្ណាទេ ស្រេចតែបងប្អូនឱ្យពិន្ទុចុះ តែក្រុមខ្ញុំរវល់ច្រើនណាស់ដែរ ។

**១៦-** ប៊ុន ស៊ុន : រីករាយនឹងឃើញទាហានចាស់ជាច្រើនមកចូលរួមថ្ងៃនេះ នេះជាកិត្តិយសមួយដែលខ្ញុំជានាយទាហានចាស់ខាងវិស្វកម្មដែរនោះ បានត្រូវគេអញ្ជើញមកឱ្យឃើញខ្មែរយើងរួបរួម ចេះចង់ជួយគ្នាទៅវិញទៅមក ។

**១៧-** ដានី : ខ្ញុំបើកកន្លែងកំសាន្តមួយឈ្មោះ "ជួបភ័ក្ត្រជំពាក់ស្នេហ៍ " សម្រាប់ជូនបងប្អូនកំសាន្ត នៅ "សាយហ្គនម៉ាក់ស៊ីម " ហើយខ្មែរយើងអាចមកកំសាន្តសម្រាកកាយពីការងារបាន ។

**១៨-** សុភា : ខ្ញុំជាលេខាម្នាក់នៃហាងរបស់នាងខ្ញុំ ខ្ញុំចង់ឃើញហាងខ្មែរច្រើន ចង់ឃើញកូនខ្មែររៀនជាប់មហាវិទ្យាល័យច្រើន មានទីកន្លែងក្មេងៗខ្មែរអាចចូលកំសាន្តឱ្យបានច្រើនកន្លែង ពីព្រោះសាសន៍គេផ្សេង គេមានកន្លែងសំរាប់កូនគេ យើងក៏ត្រូវមានរបស់យើង ហើយយើងគួរនាំគ្នាគាំទ្រគំនិតនេះ ដូចយើងកំពុងធ្វើថ្ងៃនេះ ។

**១៩-** រឿម ឡុង : ខ្ញុំសូមសរសើរបំផុតហើយ ដែលយើងចេះអង្គុយពិភាក្សាគ្នា ស្វែងរកភាពរីកចំរើន នេះជាលើកទី១ហើយ ដែលយើងនាំគ្នាស្វែងរកអ្វីមួយក្នុងភាពស្និតស្នាល ។

**២០-** សុបិន : ពិធីករ និងជាអ្នកថតរូប : លើកក្រោយ " ក្លឹបព័តិមាន " នឹងប្រព្រឹត្តទៅនៅភោជនីយដ្ឋាន "គោលដិន ប៉ាឡាស " ដដែល នៅថ្ងៃ អាទិត្យ ទី២៥ មករា ឆ្នាំ២០០៩ វេលាម៉ោង១២ថ្ងៃត្រង់ ៕

**ខ្មែរប៉ុស្តិ៍**


ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ត "អង្គរ"
4835 N. 16th Street.
Philadelphia, Pa 19141
Tel : (215) 455-7810
Ricky : (215) 485-1425
Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ
RICKY
Hand Ph.: Ricky 215-485-1425
មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អិនស្វ៉ិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C









បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើមកបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

From :Philadelphia



# Happy Holidays

## ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe`s Auto Service

State and Emission Inspection General Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY




-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកំរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

# MANN Tureral Home.INC

219 West Tabor Road.Philadelphia,PA 19120
SINCE 1909...INCOMPABLE SERVICE TO THE ENTIER DELAWARE VALLEY
Henry S.Mann,1915-1993 Phone: **(215)548-3282**
H.Craig Mann, Supervisor Fax: **(215)548-0347**

## ឈាបនដ្ឋាន "ម៉េន"

☯ បំរើសហគមន៍តាំងពី១០០ឆ្នាំមកហើយមានទីកន្លែងសមរម្យធ្វើពិធីតំកល់សព

☯ មានក្តារមឈូសអាចបូជា ឬបញ្ចុះសពនៅ២០ឆ្នាំចុងក្រោយនេះ យើងមានសេវាបំរើសហគមន៍ខ្មែរឱ្យអាចធ្វើបុណ្យតាមប្រពៃណីជូនដំណើរអ្នកដែលបានចែកឋានទៅ ។

បើសិនមានសំណួរ សូមទាក់ទងទៅ :

Craig man(715)548-3782

**Buy** something... **Sell** something...**Announce** something...**advertise** on the **Khmer Post Classifieds!**

### ប្រវត្តិសាស្ត្រនៃកម្ពុជា

លោក វ៉ាន់ឌីកាអុន ទើបនឹងសរសេរសៀវភៅប្រវត្តិសាស្ត្រនេះ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល ។ ភាគទី1 បានសរសេចប់ចេញផ្សាយរួច ហើយនៅប្រទេសបារាំង ។ រីឯភាគទី2 នឹងចេញផ្សាយបន្តទៅទៀត នាពេលឆាប់ៗនេះ ។

រីឯប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្នមួយទៀត ជាថាស ស៊ីឌី ដែលរៀបរៀងដោយ ពិន សំខុន ហើយផ្សព្វផ្សាយ នៅវិទ្យុសម្លេងខ្មែរ-អាមេរិកាំង។ ថាស ស៊ីឌី ចំនួនបួន ម៉ោងស្តីពីប្រវត្តិកម្ពុជា ចាប់តាំងពីសម្តេចនរោត្តម សីហនុ បានធ្លាក់ពីអំណាចនាឆ្នាំ 1975 មកដល់ ឆ្នាំ2004 ឆ្នាំដែលព្រះអង្គបានដាក់រាជសម្បត្តិថ្វាយព្រះរាជបុត្រារបស់ព្រះអង្គព្រះនាម នរោត្តម សីហមុនី ។

ស៊ីឌីនេះ មានលក់នៅខ្មែរប៉ុស្តិ៍ និងនៅវិទ្យុសម្លេង ខ្មែរ- អាមេរិកាំង តម្លៃ $30 ។

សូមទូរស័ព្ទមកសុបិន **(267) 253 3947 ។**

**Your Advertisement Is Here For Less than $10 for two weeks!**

## HAIR SALON FOR SALE

Good Location in the Shopping, busy traffic area.
Red Lion and Verree Road.
18 years established.
Earn instance income
$68,000
2,000 sqt.
Call Tim @ 215-776-4174 for showings.

**លក់** $68.000

➪ហាងកាត់សក់ អ៊ុតសក់ កំពុងដំណើរការណ៍ល្អ ។
➪ហាងស្ថិតនៅកន្លែងល្អ ក្នុងតំបន់ពាណិជ្ជកម្ម មានមនុស្សចេញចូលច្រើន ។
បើក 18ឆ្នាំហើយ មានទំហំ 2000Sqt ស្ថិតនៅជ្រុងផ្លូវ Red Lion និង Verree.
ហៅរក ធីម : (215) 776-4174 ដើម្បីបង្ហាញហាង ។

**Clip & Fax This Classified Coupon**

Classified Advertising
Name your category: Sales, Services, Fund Raisers...etc.
Our rates: $5.00 for up to 22 words
15 cents each additional words
Send us your ad in one of the following ways:
1. by Fax to (215) 722-2226
2-by mail to the Khmer Post 5730 Rising Sun Avenue. Philadelphia, Pa 19120
3-By phone (267) 253-3947
Payments methods: check or money order.

Name:..................Address:..............................
City:.......................State:..............................
Zip:...........................................................
Phone:.....................Fax:...............................
Your Advertisement Message:
...................................................................
...................................................................
...................................................................



# ហោរាសាស្ត្រប្រចាំខែ មករា ថ្ងៃទី ០៩-១៩



### ឆ្នាំជូត : (ពពួកទេព្ដាប្រុស ធាតុទឹក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ច ការងារអ្វីក៏ដោយក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករ អ្នករកស៊ីជួញដូរនឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ព្រមទាំងមានទ្រព្យ ហូរចូលជាហូរហែទៀតផង ៕



### ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គ ត្រូវបានសាបរលាបជាបណ្ដើរៗ ដូច្នេះលោកអ្នកអាចប្រកបកិច្ចការងាររកស៊ីបានពេញដៃពេញជើង ។ ចំពោះអ្នកជំនួញជួញដូរ បើមានប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានច្បាស់លាស់ ទើបពុំមានរឿងឆបោកកើតឡើង ៕



### ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



### ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងបំផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានការយល់ចិត្តគ្នាល្អ គ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕



### ឆ្នាំរោង : (ពពួកទេព្ដាប្រុស ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់ៗមួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊យធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯងឡើយ ប្រយ័ត្នបានជួបគ្រោះភ័យ ៕



### ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួន ឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញឹក បើរពួកកុំទៅញយ ទើបចំណងស្នេហាអាចគង់វង្សបានយូរអង្វែង ៕



### ឆ្នាំមមី : (ពពួកទេព្ដាស្រី ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេងៗ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕



### ឆ្នាំមមែ : (ពពួកទេព្ដាស្រី ធាតុមាស)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិក កម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬថៅកែ ព្រមទាំងអ្នករួមការងារជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕



### ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្ដិតស្នាមមេដៃផ្សេងៗ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិច អាចបង់ខាតផលប្រយោជន៏ច្រើន ៕



### ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ឱកាសល្អៗបានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវតែរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលា ជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈខែនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



### ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិតប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ចំពោះស្វាមីភរិយាវិញ មានភាពល្អូកល្អឺនគ្នាណាស់ ពិសេសនោះ ស្រលាញ់គ្នាលើសមុនទៅទៀត ៕



### ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ច-ការងារអ្វីក៏ដោយ ក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះៗចោមរោមស្រលាញ់ រហូតឈានដល់ការស្ដីដណ្ដឹងយកធ្វើជាគូអនាគតទៀតផង ៕

The Khmer Post is the only Cambodian Newspaper that available to reach out over 30,000 Cambodian readers who live in Philadelphia.



"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយ ដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a of year contract by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
**(267) 253-3947**
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**

## បណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍

ខ្ញុំចង់ឱ្យ " ខ្មែរប៉ុស្តិ៍ " ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយពត៌មានក្នុងសហគមន៏ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាសយដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :............................................................
អាសយដ្ឋាន :.....................................................
..........................................................U.S.A.
ទូរស័ព្ទ :..........................................................
អ៊ីមែល :...........................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួនមួយខែតម្លៃ ៥ ដុល្លារ ×........(ចំនួនមួយខែ) =..................

U.A.M.G 5730 Rising Sun Avenue Philadelphia,PA 19120
**Phone / Fax : (215) 722-2226**

## Legal Workshop

## សិក្ខាសាលាអំពីផ្លូវច្បាប់

**You and your family are invited to attend this FREE workshop on the following topics:**

**Immigration**
**Injury**
**Earned Income Tax Credit (EITC)**

**Date:** Saturday, Jan. 17th, 2009
**Time:** 10:00 AM - 12:00 PM
**Location:** Cambodian Association
5412 North 5th Street
Philadelphia, PA 19120

**Get your questions answered by a legal expert! Refreshments will be served.**

យើងខ្ញុំសូមអញ្ជើញអ្នក និងគ្រួសារមកចូលរួមក្នុងកម្មវិធីសិក្ខាសាលាដែលទាក់ទងនឹងប្រធានបទ ដូចខាងក្រោម :

អន្តោប្រវេសន៍
គ្រោះថ្នាក់ផ្សេងៗ
លុយពន្ធដារដែលអ្នកត្រូវបានមកវិញ

កាលបរិច្ឆេទ : ថ្ងៃសៅរ៍ ទី១៧ ខែមករា ឆ្នាំ២០០៩
ម៉ោង : 10:00 ព្រឹក - 12:00 ថ្ងៃត្រង់
ទីកន្លែង : សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វា
5412 North 5th Street
Philadelphia, PA 19120

សំនួរផ្សេងៗទាំងឡាយរបស់អ្នកនឹងត្រូវបានឆ្លើយដោយអ្នកជំនាញផ្លូវច្បាប់ ។ និងមានបំរើជូនទូវភេសជ្ជៈ ។

**Cambodian Association**
សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វា

For more information, please contact :
សំរាប់ពត៌មានបន្ថែមសូមទាក់ទងមក :
Ms. Cindy Suy
cindy@cagp.org
(215) 324-4070



# បន្ទប់បរិយាកាស
## សូមពិសាភេសជ្ជៈមួយកែវ
## នៅបារ៍ TIPSY LOUNGE

ជាហាងកូនខ្មែរធំជាងគេបំផុត នៅតំបន់ហ្វីឡាខាងជើង
ធិបស៊ី មាន "បារ៍" មាន "ឡោនជ៍"
ទទួលភ្ញៀវនឹងរាំកំសាន្តយ៉ាងសប្បាយរីករាយ



ធិបស៊ី នឹងនាំឱ្យលោកអ្នកចង់រាំកំសាន្ត

Live D.J. every Fri & Sat night from 9 p.m. – 2 p.m. (pool table)
Serve Chinese and American food open for Lunch and Dinner

មានក្រុមតន្ត្រីសម័យ ឬ DJ ចាក់ចម្រៀងពីរោះៗឱ្យស្តាប់
រៀងរាល់រាត្រី ថ្ងៃសុក្រ-ថ្ងៃសៅរ៍ ពីម៉ោង ៩ យប់ ដល់ម៉ោង ២ ភ្លឺ
មានតុបុកប៊ីយ៉ាទៀតផង

**Ralph Rinn**
**Tel: 215.305.5763**
**Cell: 267.968.3413**
**Michael Lay (General Manager)**
**215.409.4772**
**Email: tipsybar@gmail.com**

**Sun-Thu: 10 – 12 a.m.**
**Fri & Sat: 10 – 2 a.m.**
**Kitchen Open Daily**
**Sun-Sat: 10 – 11 p.m.**
**3904 Frankford Ave.**
**Philadelphia, Pa 19124**




សូមរង់ចាំរាំកំសាន្ត នៅថ្ងៃទី១០ មករា ២០០៩ និង ទី១៤ កុម្ភៈ ២០០៩
ថ្ងៃ VALENTINE ជាមួយក្រុមតន្ត្រីដ៏ឆ្នើមតែមួយ នៅហ្វីឡាដែលហ្វៀរ
គឺ "មនោរម្យតន្ត្រី" ចូលរួមច្រៀងដោយអ្នកចម្រៀងមកពីស្រុកខ្មែរថែមទៀតផង ២
"មនោរម្យតន្ត្រី" អាចលេងកំដរពិធីការ, បុណ្យកំណើត ឬពិធីផ្សេងៗ តាមសំណើរបាន
សូមហៅលេខ ស៊ិន ទូច : (267) 970 0411